**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៩)

ភាគីដាក់ឯកសារ: ក្រុមការពារក្ដីរបស់អ្នកស្រី អ៊ឹម ចែម

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-June-2018, 09:05
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ប្រភេទចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុប *ដីកាដំណោះស្រាយ (សម្អាងហេតុ)* ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃ *ដីកាដំណោះស្រាយ (សម្អាងហេតុ)***

---

**ដាក់ដោយ÷**

**សហមេធាវី**

ប៊ិត ស៊ាងលឹម

Wayne JORDASH, QC

**ផ្ញើជូន÷**

**ចៅក្រមអង្គបុរេជំនុំជម្រះ÷**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម BAIK Kang Jin

ចៅក្រម ន័យ ថុល

ចៅក្រម Oivier BEAUVALLET

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា÷**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/១**

## I. សេចក្តីផ្តើម

១. អ្នកស្រី អ៊ឹម ចែម តាមរយៈសហមេធាវីរបស់អ្នកស្រី (“ក្រុមការពារក្តី”) តទៅនេះ សូមដាក់ជូននូវចម្លើយតបទៅនឹង *បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ)* (“បណ្តឹងឧទ្ធរណ៍”)[1] ។

<u>បណ្តឹងឧទ្ធរណ៍ជាសង្ខេប</u>

២. នៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យ i) ដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញជាសំណៅសាធារណៈ នូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត *លើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សម្អាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ ស.ច.ស ជាសាធារណៈ* (“ដីកាសម្រេចរងការជំទាស់”)[2] និង ii) សុំបដិសេធដីកាសម្រេចរងការជំទាស់ និងស្នើសុំឱ្យដាក់ដីកាដំណោះស្រាយ (សំអាងហេតុ) ជាសាធារណៈ ដោយកោសលុបតែចំណុចចាំបាច់ដើម្បីការពារសាក្សី និងជនរងគ្រោះដូចដែលបានតម្រូវតែប៉ុណ្ណោះ[3] ។

៣. ក្នុងការគាំទ្រសំណើនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានបញ្ជាក់ឱ្យឃើញពីមូលហេតុនានា ដែលនាំឱ្យមានការរំលោភលើផលប្រយោជន៍សាធារណៈក្នុងការទទួលបានព័ត៌មានទាំងស្រុងស្តីពីដីកាដំណោះស្រាយ (សំអាងហេតុ) ហើយថាគ្មានហេតុផលណាបង្ហាញឱ្យឃើញពីភាពត្រឹមត្រូវនៃដីកាសម្រេចនេះទេ ។ ចំណុចជាក់លាក់សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង: i) លើបញ្ហាអង្គច្បាប់ដែលពាក់ព័ន្ធ និងគោលការណ៍តម្រូវឱ្យមានការចុះផ្សាយនូវដីកាដំណោះស្រាយ (សំអាងហេតុ) ពេញលេញ[4] និង ii) លើបញ្ហា

---

[1] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សម្អាងហេតុ) ឬ តាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (សម្អាងហេតុ) ធ្វើនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D309/2/1/2** ។

[2] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៦(ក) ។

[3] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦៣ និង ៦៦(ខ) ។

[4] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៩-៤២ ។

ដែលថាសហចៅក្រមស៊ើបអង្កេតខកខានមិនបានផ្តល់សំអាងហេតុដែលគួរឱ្យពេញចិត្ត ក្នុងការសម្រេចកោសលុប[5] ។

ចម្លើយតបជាសង្ខេប

៤. ក្រុមការពារក្តីមិនជំទាស់នោះទេលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់ចំណាត់ថ្នាក់ឡើងវិញជាឯកសារសាធារណៈ រួមមានដូចជា ដីកាសម្រេចដែលរងការជំទាស់ បណ្តឹងឧទ្ធរណ៍ និងចម្លើយតបនេះ សូម្បីតែការស្នើសុំឱ្យមានការកោសលុបតែចំណុចចាំបាច់មួយចំនួន[6] ។

៥. ទោះជាយ៉ាងណាក៏ដោយ ក្រុមការពារក្តីយល់ឃើញថាសំណើទាំងឡាយដែលនៅសេសសល់ទាំងអម្បាលម៉ានក្នុងបណ្តឹងឧទ្ធរណ៍នេះគួរត្រូវបានច្រានចោល ដោយសារតែៈ

(i) សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានអនុវត្តនូវបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ និងករណីដែលគាត់មិនបានធ្វើការចង្អុលបង្ហាញនូវកំហុសអង្គច្បាប់ និង/ឬកំហុសអង្គហេតុដូចការចោទប្រកាន់ កើតចេញពីការរំលោភបំពានអំណាចឆន្ទានុសិទ្ធិដែលតម្រូវឱ្យមានអន្តរាគមន៍ពីសំណាក់អង្គបុរេជំនុំជម្រះ ។

(ii) ការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) បច្ចុប្បន្ននេះ មិនបានរំលោភបំពានលើផលប្រយោជន៍សាធារណៈ ក្នុងការទទួលបានព័ត៌មានស្តីពីសេចក្តីសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតទេ ។

(iii) លក្ខណៈដាច់ខាតនៃដីកាលើកលែងការចោទប្រកាន់ តម្រូវឱ្យធ្វើការកោសលុបក្នុងកម្រិតមួយប្រដំប្រសងគ្នានឹងការកោសលុបផ្សេងៗទៀត ដែលមានស្រាប់នាពេលបច្ចុប្បន្ន ។

(iv) ការដកចេញការកោសលុបនៃដីកាដំណោះស្រាយ (សំអាងហេតុ) នឹងរំលោភលើសិទ្ធិអ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានជីវិតឯកជន ក៏ដូចសិទ្ធិទទួលបានការសន្មតថាគ្មានទោស និង

(v) សេចក្តីសន្និដ្ឋានទាំងឡាយនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ)ដែល *ហួសពីដែន*

---

[5] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៣-៦២ ។

[6] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២, កថាខណ្ឌ ៦៤ និង កថាខណ្ឌ ៦៦(ក) ។

*អំណាចច្បាប់* គួរតែរក្សាទុកការកោសលុបឱ្យនៅដដែល ។

៦. ចុងក្រោយ ដើម្បីធានានូវការអនុវត្តស្របគ្នាចំពោះការពិចារណាសំខាន់ៗ ដែលត្រូវធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតនៅពេលសម្រេចអនុវត្តលើការកោសលុប ក្រុមការពារក្ដីស្នើសុំធ្វើការកែសម្រួលបន្តិចបន្តួចលើសំណៅកោសលុបសាធារណៈបច្ចុប្បន្ន នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ។

## II. សាវតាពាក់ព័ន្ធ

៧. នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានដាក់ចេញផ្នែកសេចក្ដីសម្រេចនៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤/១ ដោយលើកលែងនូវរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ព្រោះតែកង្វះយុត្តាធិការបុគ្គល[7] ។ នៅក្នុងសេចក្ដីប្រកាសព័ត៌មានទាក់ទងនឹងបញ្ហានេះ សហចៅក្រមស៊ើបអង្កេតបានបង្ហាញថា ពួកគាត់នឹងចុះផ្សាយសេចក្ដីសន្និដ្ឋានលើអង្គច្បាប់សំខាន់ៗ[8] ។

៨. នៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចេញនូវសំណើសុំធ្វើការចុះផ្សាយ*ក្នុងចំណោមនោះ* គឺជាសេចក្ដីសំអាងហេតុពេញលេញនៃដីកាសម្រេចលើកលែងការចោទប្រកាន់នៅក្នុងសំណុំរឿង០០៤/១ រួមបញ្ចូលទាំងសំអាងហេតុពាក់ព័ន្ធនឹងធាតុសំខាន់ៗនៃបទចោទប្រកាន់នានាប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម គប្បីត្រូវធ្វើឡើងជាសាធារណៈ[9] ។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ ក្រុមការពារក្ដីបានតវ៉ាថា សំណើសុំចុះផ្សាយដែលធ្វើឡើងនៅមុនការចេញដីកាលើកលែងការចោទប្រកាន់ដូច្នេះ គឺជាការធ្វើទៅឆាប់ពេក និងគួរតែត្រូវបដិសេធចោលនៅក្នុង

---

[7] ដីកាដំណោះស្រាយ (លើផ្នែកសេចក្ដីសម្រេច) ចុះនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧, ឯកសារ **D308** ។

[8] សេចក្ដីប្រកាសព័តមាន 'សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំង អ៊ឹម ចែម' ចេញផ្សាយថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧, អាច ចូលមើលបាននៅ: https://www.eccc.gov.kh/articles/39515 ។

[9] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ត្រូវធ្វើឡើងជាសាធារណៈ ធ្វើនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៧, ឯកសារ **D309** ("សំណើសុំចុះផ្សាយជាសាធារណៈ") នៅកថាខណ្ឌ ១-៨ និង ១០ ។

ដំណាក់កាលនេះ[10] ។

៩. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយនៃសំណុំរឿង០០៤/១ ដែលមានសំអាងហេតុពេញលេញ និងសម្រេចច្រានចោលបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម[11] ។

១០. នៅថ្ងៃដដែលនេះ សំណៅកោសលុបសាធារណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) ត្រូវបានដាក់ផ្សាយ "សម្រាប់ជាផលប្រយោជន៍នៃការផ្តល់ព័ត៌មានឱ្យបានពេញលេញទៅលើកំណត់ហេតុសាធារណៈពាក់ព័ន្ធទៅនឹងការទម្លាក់ចោលការចោទប្រកាន់ប្រឆាំងនឹង [អ្នកស្រី] អ៊ឹម ចែម"[12] ចំណែកឯសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើសុំឱ្យមានការចុះផ្សាយនេះត្រូវបានទុកជាមោឃៈ[13] ។

១១. នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីជូនដំណឹងនៃការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំដាក់ជាធារណៈ នូវដីកាដំណោះស្រាយមានសំអាងហេតុ[14] ។ នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១៧ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជាភាសាអង់គ្លេស[15] ។ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៧ ភាគីពាក់ព័ន្ធត្រូវបានជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍នេះ ជាភាសាខ្មែរ ។

---

[10] ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សេចក្តីសំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ជាសាធារណៈ (D309) ធ្វើនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧, ឯកសារ **D309/1** ។

[11] ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D308/3** ("ដីកាដំណោះស្រាយ (សំអាងហេតុ)") ។

[12] ដីកាសម្រេចលើការចេញសំណៅកោសលុបជាសាធារណៈនៃដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D312** ត្រង់កថាខណ្ឌ ៣ ។

[13] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់សំអាងហេតុនៃដីកាដំណោះស្រាយ និងដីកាសម្រេចរបស់ សចស ជាសាធារណៈ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ **D309/2** ត្រង់កថាខណ្ឌ ២០ ។

[14] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំសំអាងហេតុនៃដីកាដំណោះស្រាយធ្វើឱ្យទៅជាសាធារណៈ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ **D309/2/1** ។

[15] បណ្តឹងឧទ្ធរណ៍ ។

## III. ច្បាប់ជាធរមាន

### ក. ភាពសម្ងាត់នៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ

១២. វិធាន ៥៦(១) ចែងថា ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ ហើយបុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួររបស់តុលាការត្រូវរក្សាឱ្យបាននូវការសម្ងាត់ ។ ទោះជាយ៉ាងណាក្តី អនុលោមតាមវិធាន ៥៦(២) សហចៅក្រមស៊ើបអង្កេតអាចចេញផ្សាយព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងកិច្ចស៊ើបសួរ ប្រសិនបើពួកគាត់យល់ឃើញថាជាការចាំបាច់ ដើម្បីឱ្យសាធារណៈជនបានដឹងពីកិច្ចដំណើរការនីតិវិធី ឬផ្តល់ការអនុញ្ញាតរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចនីតិវិធីស៊ើបសួរ ។

### ខ. សិទ្ធិមានជីវិតឯកជន

១៣. មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាចែងថា “ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ”[16] ។

១៤. វិធាន២១ ការពារនូវផលប្រយោជន៍របស់ជនត្រូវចោទគ្រប់ពេលវេលា នៅពេលត្រូវបកស្រាយពីបទប្បញ្ញត្តិនានាដែលអនុវត្តបាននៅ អ.វ.ត.ក[17] ។

១៥. មាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[18] ដែលអនុវត្តបាននៅ អ.វ.ត.ក[19] ចែងថា:

---

[16] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (អនុម័តនៅថ្ងៃទី២១ ខែ កញ្ញា ឆ្នាំ១៩៩៣, វិសោធនកម្មនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៩៩) មាត្រា៣៨ ។

[17] វិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី៩) ធ្វើនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ (វិសោធនកម្មធ្វើនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥) (“វិធានផ្ទៃក្នុង”) វិធាន២១(១) ។

[18] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (អនុម័តនៅថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាននៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦) លេខ 999 UNTS 171 (“ICCPR”) ត្រង់មាត្រា១៧ ។

[19] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីលើឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”), មាត្រា ៣៣ថ្មី ។

១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ ។

២. ជនគ្រប់រូបមានសិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។

## គ. ការចុះផ្សាយនូវឯកសារសម្ងាត់

១៦. មាត្រា ៩.១ នៃចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ចែងពីវិធាននៃការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដូច្នេះថា:

ឯកសារ ឬព័ត៌មានអាចត្រូវបានចាត់ប្រភេទសារឡើងវិញ (និងដាក់ទៅក្នុងផ្នែកនៃសំណុំរឿងដែលមានកម្រិតសម្ងាត់ខុសគ្នា) អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមករណីសមស្រប ។

១៧. មាត្រា ១.២ នៃសេចក្តីណែនាំអនុវត្ត ស្តីពីចំណាត់ប្រភេទ[ឯកសារ] និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿងចែងថា:

គោលការណ៍ដែលនាំឱ្យមានសេចក្តីណែនាំអនុវត្តនេះ គឺជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបសួររបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីតុលាការ ដែលមិនបើកចំហរដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែល ។

១៨. មាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ចែងថា:

តម្រូវតាមផលប្រយោជន៍យុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ

---

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើនៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣, មាត្រា ១២(២) ។

ដែលគ្រប់គ្រងសំណុំរឿង អាចដាក់ចំណាត់ប្រភេទឯកសារជាថ្មីក្នុងសំណុំរឿង [ចំណែក] ភាគីជាប់ពាក់ព័ន្ធនឹងត្រូវផ្តល់ឱកាសឱ្យបានដឹង និងធ្វើការឆ្លើយតប មុនមានការធ្វើសេចក្តីសម្រេចបែបនេះ ឬអំឡុងពេលដាក់ចំណាត់ប្រភេទជាថ្មី បណ្តោះអាសន្ន ដែលជាការចាំបាច់ក្នុងការការពារព័ត៌មានដែលអាចជាព័ត៌មាន សម្ងាត់ ឬសម្ងាត់បំផុត ។ នៅក្នុងករណីនេះ ភាគីពាក់ព័ន្ធនឹងសំណុំរឿងត្រូវបាន ជូនដំណឹងអំពីការដាក់ចំណាត់ប្រភេទជាថ្មីបណ្តោះអាសន្ន និងអំពីសេចក្តី សម្រេចដាក់ចំណាត់ថ្នាក់ជាថ្មី ។

## ឃ. ការកោសលុបផ្នែកខ្លះនៃសារណា

១៩. មាត្រា ៩ នៃចំណាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ចែងពីវិធាននៃ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញ និងកាត់ចេញផ្នែកខ្លះនៃសារណា ដូច្នេះថា:

៩.២ អត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់បំផុតអាច ត្រូវគេរៀបចំឡើងដើម្បីដាក់ក្នុងផ្នែកសាធារណៈនៃសំណុំរឿង តាមការណែនាំ របស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតាមករណីសមស្រប ។ អត្ថបទ ឯកសារសាធារណៈថ្មីអាចនឹងត្រូវរៀបចំតាមរយៈ ៖

ក. បង្កើតច្បាប់ចម្លងពីឯកសារច្បាប់ដើម ។

ខ. កាត់ចេញពីផ្នែកនៃច្បាប់ចម្លងព័ត៌មានសម្ងាត់ និងសម្ងាត់បំផុតទាំង អស់ដែលអាចធ្វើបាន ។ និង

គ. បញ្ជូនអត្ថបទដែលបន្ទាប់ពីបានកាត់ចេញមកនោះ ទៅសហចៅក្រម ស៊ើបអង្កេត ឬអង្គជំនុំជម្រះដើម្បីពិនិត្យឡើងវិញ និងសម្រេចមុននឹង ដាក់ឯកសារទាំងនោះចូលទៅក្នុងផ្នែកសាធារណៈនៃសំណុំរឿង ។ អត្ថបទឯកសារសម្ងាត់នៃឯកសារសម្ងាត់បំផុត អាចត្រូវគេរៀបចំ ឡើងតាមរបៀបប្រហាក់ប្រហែលគ្នានេះដែរ ។

៩.៣ បើសិនអត្ថបទឯកសារសាធារណៈនៃឯកសារសម្ងាត់ ឬសម្ងាត់ បំផុតត្រូវបានរៀបចំឡើងតាមសំណើភាគីមួយ ការកាត់ចេញផ្នែកណាខ្លះ ណាមួយ ត្រូវធ្វើឡើងដោយភាគីស្នើសុំ និងដាក់ស្នើសុំការអនុញ្ញាតដោយ

អនុលោមតាមមាត្រា ៩.២ (គ) ។

២០. មាត្រា ៣(១)(ឃ) នៃសេចក្តីណែនាំការអនុវត្តពីវិធានការពារតម្រូវថា រាល់ព័ត៌មានទាំងឡាយណាដែលអាចនាំឱ្យមានការកត់សម្គាល់នូវអត្តសញ្ញាណរបស់បុគ្គលដែលត្រូវការពារ ឬព័ត៌មានផ្សេងទៀតដែលអាចបង្ហាញអំពីអត្តសញ្ញាណ ឬទីកន្លែង គឺត្រូវដកចេញពីកំណត់ហេតុ ។

## IV. ចម្លើយតប

២១. ក្រុមការពារក្តីយល់ស្រប ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិត្រង់ការលើកឡើងពីកម្រិតចំណាប់អារម្មណ៍របស់សាធារណជនចំពោះសំណុំរឿង ០០៤/១[20] ។ ទោះជាយ៉ាងណាក្តី ផ្ទុយពីមូលដ្ឋានសំអាងនៅក្នុងបណ្តឹងឧទ្ធរណ៍ ការផ្តល់ព័ត៌មានសម្រាប់សាធារណជន ទាមទារឱ្យប្រើវិធីសាស្ត្រប្រកបដោយភាពផ្ចិតផ្ចង់ និងដោយការប្រុងប្រយ័ត្នដើម្បីឱ្យមានតម្លាភាព ដែលវាក៏តម្រូវឱ្យគោរពផងដែរនូវភាពចាំបាច់ក្នុងការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ក៏ដូចជាសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបាននូវការសន្មតថាគ្មានទោស ព្រមទាំងសិទ្ធិនៃការមានជីវិតឯកជន និងកេរ្តិ៍ឈ្មោះរបស់អ្នកស្រី ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញឱ្យឃើញថាខ្លួនមិនខ្វល់ឡើយ លើការពិចារណានូវភាពចាំបាច់ទាំងនេះ ដោយមិនអើពើនឹងតម្រូវការធានានូវការអនុវត្តវិធីសាស្ត្រដែលមានតុល្យភាពមួយសម្រាប់ផលប្រយោជន៍ទាំងនេះ និងក៏មិនអើពើលើការកំណត់លក្ខខណ្ឌនៃការត្រួតពិនិត្យជាថ្មីនូវដីកាសម្រេចដែលរងការជំទាស់ ។ សរុបទៅ ក្រុមការពារក្តីសូមស្នើថា បណ្តឹងឧទ្ធរណ៍នេះ គួរតែត្រូវបដិសេធចោល ពីព្រោះ៖

(i) សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានអនុវត្តបទដ្ឋាននៃការត្រួតពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ ព្រមទាំងខកខានមិនបានធ្វើការចង្អុលបង្ហាញពីកំហុសអង្គច្បាប់ និង/ឬកំហុសអង្គហេតុដូចដែលគាត់បានចោទថាមានការរំលោភបំពាននូវអំណាចឆន្ទានុសិទ្ធិដែលតម្រូវឱ្យមានអន្តរាគមន៍ពីសំណាក់អង្គបុរេជំនុំជម្រះ ។

(ii) ការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) បច្ចុប្បន្ន មិនបានរំលោភបំពានលើ

---

[20] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៤ ។

ផលប្រយោជន៍សាធារណៈនោះទេ ក្នុងការទទួលបានព័ត៌មានស្ដីពីសេចក្ដីសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ។

(iii) លក្ខណៈដាច់ខាតនៃដីកាលើកលែងការចោទប្រកាន់ តម្រូវឱ្យធ្វើការកោសលុបក្នុងកម្រិតមួយប្រដំប្រសងគ្នានឹងការកោសលុបផ្សេងៗទៀត ដែលបានអនុវត្តរួចមកហើយនៅក្នុងសេចក្ដីបង្គាប់មួយចំនួន ។

(iv) ការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) តិចជាងនេះ អាចនឹងនាំឱ្យមានការរំលោភលើសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានជីវិតឯកជន ក៏ដូចសិទ្ធិទទួលបានការសន្មតថាគ្មានទោស និង

(v) សេចក្ដីសន្និដ្ឋានទាំងអស់ ដែលមិនចាំបាច់ក្នុងការកំណត់សម្រេចលើបញ្ហាយុត្តាធិការបុគ្គល គឺជាសេចក្ដីសន្និដ្ឋានដែល *ហួសពីដែនអំណាចច្បាប់* និងគួរតែត្រូវរក្សាទុកការកោសលុបឱ្យនៅដដែល ។

## ក. សហព្រះរាជអាជ្ញាអន្តរជាតិមិនអនុវត្តបទដ្ឋានត្រឹមត្រូវនៃការពិនិត្យមើលឡើងវិញ

២២. នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានធ្វើការកំណត់ពីមូលដ្ឋាន*ណាមួយ*នៃបណ្ដឹងឧទ្ធរណ៍ ហើយថាតើមានកំហុសអង្គច្បាប់ និង/ឬក៏កំហុសអង្គហេតុ*ណាមួយ* ដែលខ្លួនចង់តវ៉ា ។ បណ្ដឹងឧទ្ធរណ៍ខ្វះភាពជាក់លាក់ដែលតម្រូវឱ្យមានក្នុងការកំណត់បង្ហាញឱ្យបានគ្រប់គ្រាន់ចំពោះបញ្ហាវិវាទនានា ដោយលើកឡើងពីទឡ្ហីករណ៍យោងឱ្យបានច្បាស់លាស់ ។ ការមិនលើកឡើងនូវបញ្ហាជាក់លាក់ដូច្នេះ វាធ្វើឱ្យក្រុមការពារក្ដីបាត់បង់ឱកាសសមហេតុផលដើម្បីអាចធ្វើការឆ្លើយតបឱ្យចំបញ្ហាជាក់លាក់ទាំងនោះ[21] ។ ដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះ គួរតែត្រូវ

---

[21] *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជតក*, សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២, ឯកសារ **F28** (“សាលដីកានៃសំណុំរឿង០០១, ឯកសារ **F28**”) នៅកថាខណ្ឌ ៤១ ។ [“បទប្បញ្ញត្តិទាំងនេះ តម្រូវឱ្យគ្រប់ភាគីនៃបណ្ដឹងសារទុក្ខលើកហេតុផលរបស់ខ្លួនដោយមានទឡ្ហីករណ៍ជាក់លាក់គ្រប់គ្រាន់ ដើម្បីឱ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់បញ្ហាវិទាទដោយយោងទៅលើសំអាងហេតុជាក់លាក់របស់អង្គបុរេជំនុំជម្រះសាលាដំបូង ។ បទប្បញ្ញត្តិទាំងនេះ មានគោលបំណងមិនត្រឹមតែធានាប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ គឺ

ច្រានចោល ។

២៣. តាមរយៈការអានក្នុងគោលបំណងដើម្បីប្រមែប្រមូលនូវកង្វល់នានា ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍បានបង្ហាញឱ្យឃើញថា ជាជាងស្នេះស្វែងសុំឱ្យមានការបដិសេធនូវដីកាសម្រេចរងការជំទាស់ សហព្រះរាជអាជ្ញាអន្តរជាតិបែជាស្នេះស្វែងសុំឱ្យមានការពិចារណាសារជាថ្មីលើដីកាសម្រេចរងការជំទាស់ និងស្នើសុំឱ្យអនុវត្តការកោសលុបនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ទៅវិញ[22] ។ ការធ្វើដូច្នេះ គឺមិនត្រូវបានអនុញ្ញាតឱ្យធ្វើទៅបានឡើយ ។ បណ្តឹងឧទ្ធរណ៍

ថែមទាំងធានាថា ភាគីនីមួយៗត្រូវដឹងនូវអំណះអំណាងនានា ដែលខ្លួនអាចធ្វើការឆ្លើយតបបាន ។ ដូចដែលតុលាការ ICTY បានកត់សម្គាល់ទាក់ទិននឹងបទប្បញ្ញត្តិប្រហាក់ប្រហែលគ្នានេះនៅក្នុងវិធាននីតិវិធីរបស់ខ្លួនថា ‘ប្រសិនបើសារណាទាំងនោះមានលក្ខណៈមិនច្បាស់ ផ្ទុយគ្នា ស្រពិចស្រពិល ឬមានវិការៈខាងទម្រង់បែបបទ និងមានកំហុសខ្វះខាតជាក់ស្តែងផ្សេងទៀតនោះ គេមិនអាចរំពឹងឱ្យតុលាការការកំពូលពិចារណាលើសារណារបស់ភាគីបានលម្អិតឡើយ’ ។ ជាវិធានទូទៅច្បាប់តម្រូវឱ្យម្ចាស់បណ្តឹងសារទុក្ខបង្ហាញនូវផ្នែកនៃប្រតិចារិក ដែលខ្លួនតវ៉ាបង្ហាញនូវអំណះអំណាងក្នុងកម្រិតមួយដែលមានភាពច្បាស់លាស់សមហេតុផលជូនអង្គជំនុំជម្រះសាលាដំបូងឱ្យចំបញ្ហា និងបញ្ជាក់ឱ្យបានច្បាស់លាស់នូវទឡ្ហីករណ៍បណ្តឹងសារទុក្ខប្រឆាំងនឹងសេចក្តីសម្រេច និងអំណះអំណាងគាំទ្រសំខាន់ៗ ។ កាលណាសារណារបស់ភាគីមិនស៊ីសង្វាក់ឬខកខានក្នុងការលើកឡើងនូវខ្លឹមសារនៃទឡ្ហីករណ៍ណាមួយនៃបណ្តឹងសារទុក្ខដែលមានលក្ខណៈពិសេសគ្រប់គ្រាន់ និងអាចឱ្យអង្គជំនុំជម្រះតុលាការកំពូលមានលទ្ធភាពកំណត់បញ្ហាវិវាទបាននោះទេ នោះសារណាទាំងនេះអាចត្រូវបានប្រកាសបដិសេធចោល ដោយមានវិការៈផ្នែកនីតិវិធី” (លុបចោលសេចក្តីយោង)។] ។

[22] *សូមមើល, សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿង លេខ ០០២/១៩-០៩-២០០៧/អវកត/កសចស (អ.ប.ជ. ០៣),* សេចក្តីសម្រេចលើលើពាក្យសុំពិចារណាសារជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ **C22/I/68** ត្រង់កថាខណ្ឌ ២៥ [“ពាក្យសុំពិចារណាសារជាថ្មីអាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ដាក់ជូនអង្គបុរេជំនុំជម្រះ ដើម្បីឱ្យធ្វើការពិចារណាសេចក្តីសម្រេចរបស់ខ្លួនកាលពីលើកមុន ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសម្រេចថា អង្គជំនុំជម្រះអាចនឹង ‘ពិចារណាជាដរាបចំពោះសេចក្តីសម្រេចដែលខ្លួនបានចេញកាលពីលើកមុនសារជាថ្មី តែការពិចារណាសារជាថ្មីនេះ មិនមែនដោយសារមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះនោះទេ គឺអាចដោយសារនៅពេលខ្លួនយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌ជាអំណាច’ ។ អំណាចនេះអាចពិពណ៌នាថា ជាអំណាចឆន្ទានុសិទ្ធិ ហើយជាពិសេស អំណាចនេះជាជម្រើសចុងក្រោយដែលមានភាពចាំបាច់សម្រាប់ស្ថាប័នតុលាការដូចអង្គបុរេជំនុំជម្រះនេះ ។ ការផ្លាស់ប្តូរនូវកាលៈទេសៈអាចរួមបញ្ចូលអង្គហេតុថ្មី ឬអំណះអំណាងថ្មី ។ បទដ្ឋានចំពោះការពិចារណាសារជាថ្មីត្រូវបានពិពណ៌នាដូចតទៅ: ‘អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិដោយឯកឯង ក្នុងការពិចារណាសេចក្តីសម្រេចបន្ទាន់បង្ខំដែលបានចេញកាលពីលើកមុនសារជាថ្មី នៅក្នុងករណីពិសេស ‘ប្រសិនបើមានកំហុសចំពោះអំណះអំណាងច្បាស់លាស់ ឬប្រសិនបើចាំបាច់ក្នុងការរារាំងនូវភាពអយុត្តិធម៌’’ ។”

មួយមិនអាចនឹងយកមកប្រើប្រាស់ដូចជាសេះមកពីទីក្រុងត្រូយ៉ាន (Trojan) សម្រាប់ធ្វើការស្នើសុំឱ្យមានការពិចារណាសារជាថ្មីនូវសេចក្តីសម្រេចទាំងឡាយណា ដែលមិនស្របតាមបំណងខ្លួន ឬសេចក្តីសម្រេចទាំងឡាយណាដែលខ្លួនមិនចង់បាននោះទេ ។ ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍ត្រូវតែផ្អែកទាំងស្រុងទៅលើបទដ្ឋានត្រឹមត្រូវនៃបណ្តឹងឧទ្ធរណ៍ ជាមួយនឹងការថ្លែងសេចក្តីបង្ហាញប្រាប់ឱ្យច្បាស់ៗនូវកំហុសឆ្គងអង្គច្បាប់ និង/ឬកំហុសអង្គហេតុដែលខ្លួនរកឃើញ ហើយថាតើកំហុសទាំងនេះបង្កឱ្យមានការរំលោភបំពានឆន្ទានុសិទ្ធិរបៀបណាខ្លះ ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ ។

២៤. ដីកាសម្រេចដែលរងការជំទាស់ និងការកោសលុបមួយចំនួននោះ គឺធ្វើឡើងដោយចរិតលក្ខណៈឆន្ទានុសិទ្ធិ ។ បទដ្ឋានត្រឹមត្រូវក្នុងការពិនិត្យឡើងវិញដែលត្រូវយកមកអនុវត្តនៅក្នុងករណីនេះ គឺអាស្រ័យទៅលើការបង្ហាញនូវវិវាទមួយនៃការរំលោភឆន្ទានុសិទ្ធិ ។ វិធាន ៥៦(២) អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតចុះផ្សាយព័ត៌មានសំណុំរឿងជាសាធារណៈ[23] ។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតធ្វើដូច្នេះបានតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិ ។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះធ្លាប់បានលើកឡើងជាច្រើនលើកច្រើនសារថា:

> អង្គបុរេជំនុំជម្រះសូមបញ្ជាក់ថា ក្របខណ្ឌច្បាប់ អ.វ.ត.ក ជាពិសេសនៅក្នុងវិធាន ៥៦ នៃវិធានផ្ទៃក្នុង បានផ្តល់ឆន្ទានុសិទ្ធិទូលាយដល់សហចៅក្រមស៊ើប

---

(លុបចោលសេចក្តីយោង)] ។ អាចចូលមើលដីកាសម្រេចនៅគេហទំព័ររបស់ អ.វ.ត.ក នៅទីនេះ៖ https://www.eccc.gov.kh/sites/default/files/documents/courtdoc/C22_I_68_EN_0.pdf ។

[23] វិធាន ៥៦(២) នៃវិធានផ្ទៃក្នុង ["ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអាចៈ ក-តាមរយៈផ្នែកកិច្ចការសាធារណៈផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មានដែលនាំឱ្យមានការភ័ន្តច្រឡំ និង ខ-ក្នុងកាលៈទេសៈពិសេស ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និងបន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ។ ក្នុងករណីមិនគោរពទៅតាមលក្ខខណ្ឌណាមួយដែលសហចៅក្រមស៊ើបអង្កេតតម្រូវ វិធាន ៣៥ ដល់ ៣៨ ត្រូវយកមកអនុវត្ត ។"] ។

អង្កេតក្នុងការដោះស្រាយលើបញ្ហារក្សាការសម្ងាត់ និងផ្តល់សិទ្ធិតិចតួចក្នុងការចូលរួមក្នុងការស៊ើបអង្កេតរបស់តុលាការ[24] ។

២៥. សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ថែមទៀតថា "ការបង្ហាញផ្នែកសម្ងាត់នៃការស៊ើបសួរទៅជនដែលមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៤ គឺស្ថិតនៅក្នុងដែនកំណត់នៃឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត"[25] ។ ហេតុដូច្នេះ គ្មានអ្វីត្រូវសង្ស័យឡើយដែលថា សហចៅក្រមស៊ើបអង្កេតទទួលបានអំណាចឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ក្នុងការអនុញ្ញាតឱ្យមានការទទួលបានព័ត៌មានស្តីពីកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ ដោយសម្រេចថាតើគួរដាក់សំណៅសាធារណៈនៃដីកាដំណោះស្រាយ និងសម្រេចអនុវត្តការកោសលុបលើផ្នែកណាខ្លះ ។

២៦. អង្គបុរេជំនុំជម្រះធ្លាប់បានថ្លែងថា មិនមែនឱ្យតែរាល់កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ គឺសុទ្ធតែនាំឱ្យអង្គបុរេជំនុំជម្រះសម្រេចបដិសេធចោល នូវអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនោះទេ[26] ។ ដើម្បីអាចសម្រេចធ្វើអន្តរាគមន៍លើបណ្តឹងឧទ្ធរណ៍បាន វាទាល់តែកំហុសឆ្គង

---

[24] *សូមមើលជាឧទាហរណ៍ក្នុងសំណុំរឿង អោ អាន, សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩/អវតក/កសចស (អ.ប.ជ ២៥)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60 ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦, ឯកសារ **D284/1/4** ត្រង់កថាខណ្ឌ ២៣ ។ *សំណុំរឿង យឹម ទិត្យ, សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវតក/កសចស (អ.ប.ជ ២៦)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះនៅក្នុងសវនាការអសាធារណៈ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦, ឯកសារ **D309/6** ត្រង់កថាខណ្ឌ ២០ ។

[25] *សំណុំរឿង យឹម ទិត្យ, សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវតក/កសចស*, ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/២ ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៤, ឯកសារ **D193/1** ត្រង់កថាខណ្ឌ ១០ ។

[26] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ.៦២)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០, ធ្វើនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ **D353/2/3** ត្រង់កថាខណ្ឌ ៨ ។ *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ.៦៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជុំជាមួយលោក អៀង

នោះ *មានអានុភាពយ៉ាងខ្លាំង* លើការនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតដែលនាំឱ្យការប្តឹងឧទ្ធរណ៍[27] ។ លើសពីនេះទៀត ម្ចាស់បណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា i) មានកំហុសឆ្គងអង្គច្បាប់នាំឱ្យសេចក្តីសម្រេចគ្មានសុពលភាព ii) កំហុសឆ្គងអង្គហេតុនាំឱ្យមានភាពអយុត្តិធម៌ ឬ iii) សេចក្តីសម្រេច ឬដីកាមិនសមហេតុផលខ្លាំងដែលនាំឱ្យមានសេចក្តីសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវ [28] ។

២៧. ហេតុដូច្នេះ បើគ្មានការបង្ហាញឱ្យឃើញនូវការរំលោភបំពានអំណាចឆន្ទានុសិទ្ធិទេ នោះដីកាសម្រេចរងការជំទាស់ត្រូវតែរក្សាទុកដូចដើម ។ ការបរាជ័យរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការតវ៉ាពីការរំលោភបំពានឆន្ទានុសិទ្ធិ គឺជារឿងមហន្តរាយមួយ និងគួរតែត្រូវច្រានចោលនូវបណ្តឹងឧទ្ធរណ៍ដូច្នេះ ។

២៨. លើសពីនេះទៅទៀត ដូចលើកឡើងនៅខាងក្រោម ទាំងដីកាសម្រេចរងការជំទាស់ និងការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ត្រូវបានផ្អែកលើការបកស្រាយច្បាប់ដ៏ត្រឹមត្រូវ និងការអនុវត្តន៍ដ៏សមហេតុផលលើអង្គហេតុ ឬបើមិនដូច្នោះទេ គឺវាត្រូវបានធ្វើឡើងនៅក្នុងដែនកម្រិតនៃឆន្ទានុសិទ្ធិដ៏ពិសេសដែលពួកគាត់មាន ។ មិនថាការដែលត្រូវបានគេមើលឃើញថាសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិនៃការមានជីវិតឯកជន ឬគ្មាន

---

សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ធ្វើនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ **A371/2/12** ត្រង់កថាខណ្ឌ ២២ ។

[27] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ.៦២)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០, ធ្វើនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ **D353/2/3** ត្រង់កថាខណ្ឌ ៨ ។

[28] *សំណុំរឿង នួន ជា និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (អ.ប.ជ.៦៤)*, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជុំជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០, ធ្វើនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ **A371/2/12** ត្រង់កថាខណ្ឌ ២២ ។

ការឆោតនោះទេ ដីកាបង្គាប់ឱ្យធ្វើការកោសលុបលើផ្នែកទាំងនោះ ត្រូវបានធ្វើឡើងដោយមានភាពសមមាត្រ និងគ្រប់គ្រាន់ដើម្បីបំពេញតាមសេចក្តីត្រូវការនៃការជំនុំជម្រះជាសាធារណៈ និងក៏សមស្របទៅនឹងសារៈសំខាន់នៃសិទ្ធិដែលអ្នកស្រីត្រូវទទួលបាន ។

**ខ. សំណៅកោសលុបសាធារណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) មិនត្រូវបានរងការបំពារបំពានឡើយ បន្ទាប់ពីផលប្រយោជន៍សាធារណៈត្រូវបានបំពេញតាមរយៈការផ្តល់ព័ត៌មានស្តីពីសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតហើយនោះ**

២៩. សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា "សំណៅជាសាធារណៈនៃឯកសារនេះ ត្រូវបានកោសលុបយ៉ាងច្រើន ដើម្បីដកចេញនូវកិច្ចពិភាក្សាទាំងអស់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង និងការទទួលខុសត្រូវរបស់[អ្នកស្រី] អ៊ឹម ចែម"[29] ។ លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ច្បាប់ជាធរមានអនុវត្តនៅ អ.វ.ត.ក គាំទ្រឱ្យសាធារណជនអាចមើលដីកាដំណោះស្រាយ (សំអាងហេតុ) *ពេញលេញ* បាន[30] ។ ក្រុមការពារក្តីយល់ឃើញថា ការអះអាងយកតែឈ្នះដូច្នេះ គឺជាការធ្វើឡើងដោយមិនយកចិត្តទុកដាក់ចំពោះសារៈសំខាន់ក្នុងការរក្សាឱ្យមានតុល្យភាពត្រឹមត្រូវរវាងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន ភាពសម្ងាត់នៃការស៊ើបអង្កេត ក៏ដូចជាសិទ្ធិរបស់ជនសង្ស័យ ។ ដូចបានពិពណ៌នានៅខាងក្រោម ត្រង់កថាខណ្ឌទី៣០ ដល់ ៣៩ ដោយគិតគូរពីផលប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែងបែបនេះ ការកោសលុបរបស់សហចៅក្រមស៊ើបអង្កេត គឺមានភាពសមហេតុផល និងសមាមាត្រ ។

*i. ការទាមទាររបស់សាធារណជនលើបញ្ហាតម្លាភាពមិនសមមូលទៅនឹងការច្រានចោលជាទូទៅមួយលើការទាមទារឱ្យមានការទទួលបាននូវព័ត៌មាន*

៣០. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ការកោសលុបនៅក្នុងសំណៅសាធារណៈនៃដីកា

[29] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៥ ។ *សូមមើលផងដែរ*, បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៤ ។

[30] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២០-៤២ ។

ដំណោះស្រាយ (សំអាងហេតុ) បានបំពានលើសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានព័ត៌មាន[31] និងថា វាជាការខកខានមិនបានធ្វើឱ្យមានតម្លាភាពដូចដែលតម្រូវ[32] ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងបន្តទៀតថា តម្លាភាពនៃកិច្ចដំណើរការនីតិវិធី គឺជាគោលការណ៍សំខាន់ដែលបានកំណត់ត្រឹមតែ "ការលើកលែងដែលមានកម្រិត និងសមហេតុផល" តែប៉ុណ្ណោះ បើយោងតាមវិធាន៥៦ នៃផ្ទៃក្នុង "តាមរយៈការដាក់អាណត្តិថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរត្រូវបានកំពុងដំណើរការ បទដ្ឋានត្រូវរក្សាបាននូវការសម្ងាត់"[33] ។

៣១. ក្រុមការពារក្តីយល់ឃើញថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនត្រូវបានគាំទ្រដោយចក្ខុវិស័យសមហេតុផលនៃវិធានច្បាប់ជាធរមានដែលអនុវត្តនៅ អ.វ.ត.ក ឬស្របតាមយុត្តិសាស្ត្រតុលាការបច្ចុប្បន្ននោះទេ ។ តាមពិត ការនិយាយបញ្ច្រាសមកវិញ ទើបជាការត្រឹមត្រូវ៖ ភាពសម្ងាត់នៃកិច្ចស៊ើបអង្កេតគឺជា និងនៅតែជាវិន័យ ហើយការដាក់បង្ហាញជាសាធារណៈ គឺជាករណីលើកលែង ។ ខណៈដែលភាពសម្ងាត់នៃកិច្ចស៊ើបសួរ គឺជាគោលការណ៍សំខាន់នៅដំណាក់កាលមុនពេលជំនុំជម្រះ[34] ការរក្សានូវភាពសម្ងាត់នេះត្រូវតែធ្វើឱ្យមានតុល្យភាពទល់នឹងផលប្រយោជន៍យុត្តិធម៌[35] និងការបើកផ្លូវឱ្យសាធារណៈជនទទួលបាននូវព័ត៌មាន និងការអប់រំអំពីដំណើរការនីតិវិធីតុលាការ[36] ។ ទាក់ទងទៅនឹងតម្រូវការនៃការមានតម្លាភាព អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា:

> ការធ្វើចំណាត់ថ្នាក់លើឯកសារ ត្រូវធ្វើឡើងដោយធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងតម្រូវការនៃការរក្សាការសម្ងាត់ និងតម្រូវការនៃតម្លាភាព ដែលកើតចេញពី

---

31 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៥ ។

32 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២៣-៤២ ។

33 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២០ (លុបចោលចំណុចសង្កត់ន័យ) ។

34 *សូមមើល*, វិធាន ៥៦(១) នៃវិធានផ្ទៃក្នុង ។

35 *សូមមើល*, សេចក្តីណែនាំអនុវត្ត ស្តីអំពីការដាក់ឯកសារ ត្រង់មាត្រា ៣.១៤ ។

36 *សូមមើល*, សេចក្តីណែនាំអនុវត្ត ស្តីអំពីចំណាត់ប្រភេទ[ឯកសារ] និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង (សេចក្តីណែនាំឱ្យអនុវត្តនៅ អវតក/០០៤/២០០៩/វិ.លើកទី ២) មាត្រា ១.២ ។

គោលការណ៍ជាសារវន្ត ដែលគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាលើគោលបំណងរបស់តុលាការក្នុងការអប់រំ និងរក្សាកេរ្តិ៍ដំណែល" [37] ។

៣២. ទោះជាយ៉ាងណាក្តី នៅពេលធ្វើការថ្លឹងថ្លែងនូវសម្រេចរវាងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា មិនមានទេសិទ្ធិទូទៅសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និងសិទ្ធិសាធារណជនក្នុងការទទួលបានព័ត៌មាន:

> ក្រៅពីក្របខ័ណ្ឌ [នៃការពិនិត្យពិច័យតាមរយៈសាលាឧទ្ធរណ៍មួយចំនួន វិន័យលើផ្នែកនីតិវិធី និងការផ្តល់ព័ត៌មានត្រឹមត្រូវដល់សារព័ត៌មាន] សង្គមស៊ីវិល *ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន មិនមានសិទ្ធិទូទៅសំខាន់ជាងនេះ ត្រូវទទួលបានព័ត៌មានឱ្យហួសពីអ្វីដែលចៅក្រមមានសមត្ថកិច្ច បានសម្រេចដាក់បង្ហាញឡើយ*"[38] ។

៣៣. ការខ្វះសិទ្ធិទូទៅនេះ អនុវត្តដូចគ្នាសម្រាប់ជនរងគ្រោះ ។ នៅក្នុងសំណុំរឿង *Welke និង Bialek ទល់នឹងប្រទេសប៉ូឡូញ* (*Poland*) តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) បញ្ជាក់ថា ដីកាសម្រេចនានា អាចត្រូវបានធ្វើការកោសលុបដើម្បីធ្វើឱ្យស្របគ្នាជាមួយនឹងបទដ្ឋានសិទ្ធិមនុស្ស[39] ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានកត់សម្គាល់ថា "កម្រិតនៃភាពបត់បែន" មួយ គឺទាក់ទងទៅនឹងតម្រូវការដែលថាសាលក្រមទាំងឡាយ ត្រូវតែបានធ្វើការប្រកាសជាសាធារណៈ ដោយថ្លែងថា:

---

[37] *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជតក*, សេចក្តីសម្រេចលើគោលការណ៍ណែនាំ ស្តីពីការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១២, ឯកសារ **F30/2** ត្រង់កថាខណ្ឌ ៥ ។

[38] *សំណុំរឿង យឹម ទិត្យ, សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩/អវតក/កសចស*, ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៧, ឯកសារ **D355/9** ត្រង់កថាខណ្ឌ ១៣ (ចំណុចគ្រេតគឺជាការសង្កត់ន័យបន្ថែម) ។

[39] *សំណុំរឿង Welke និង Bialek ទល់នឹង ប្រទេសប៉ូឡូញ* (ពាក្យសុំលេខ 15924/05), តុលាការសិទ្ធិមនុស្សអឺរ៉ុប, ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១១, ត្រង់កថាខណ្ឌ ៨៣-៨៤ [ភ្ជាប់ជា**ឯកសារសំអាង ១**] ។

"ទម្រង់បែបបទនៃការចុះផ្សាយជាសាធារណៈ... ត្រូវតែទទួលបាននូវការវាយតម្លៃឱ្យស្របទៅតាមលក្ខណៈពិសេសនៃដំណើរការនីតិវិធីដែលបានចោទឡើង[40] ។ តុលាការបានចាត់ទុកថា ការប្រកាសជាសាធារណៈដែលរាប់បញ្ចូលទាំង "ផ្នែកប្រតិបត្តិការ" នៃសាលក្រមទាំងនោះ មានភាពគ្រប់គ្រាន់នៅក្នុងកាលៈទេសៈមួយចំនួន[41] ។

៣៤. លើសពីនេះ ដែលវាផ្ទុយទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[42] គោលដៅចម្បងរបស់ អ.វ.ត.ក មិនរួមបញ្ចូលនូវ 'កាតព្វកិច្ចនៃប្រវត្តិសាស្ត្រ' ឬ 'កាតព្វកិច្ចធ្វើឱ្យមានការចងចាំ' នោះទេ ប៉ុន្តែមានមុខងារគ្រាន់តែដើម្បីធ្វើការផ្តន្ទាទោសលើជនទាំងឡាយណា ដែលត្រូវបានរកឃើញថាជា "មេដឹកនាំជាន់ខ្ពស់" ឬជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងវង្វង់ដែនយុត្តាធិការរបស់ អ.វ.ត.ក ។ ដើម្បីគាំទ្រការចោទប្រកាន់របស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការអះអាង តាមរយៈការយោងលើសំណេរផ្ទាល់ខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដែលជាផ្នែកមួយនៃបេសកកម្មរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី គឺត្រូវបានបង្កើត "កំណត់ត្រាប្រវត្តិសាស្ត្រមួយនូវអ្វីដែលបានកើតឡើងអំឡុងពេលមានជម្លោះនៅទីនោះ ដោយទប់ស្កាត់ការបកស្រាយកំណត់ត្រាប្រវត្តិសាស្ត្រឡើងវិញ"[43] ។ ទីមួយ ពាក្យពេចន៍ទាំងនេះមិនមែនជាការថ្លែងរបស់សហចៅក្រមស៊ើបអង្កេតទេ តែវាជាពាក្យសម្តីរបស់មេធាវីមួយរូប គឺលោក Michael Karnavas[44] ។ ទីពីរ ឃ្លាបន្ទាប់ពីការយោងនេះតែម្តង

---

[40] *សំណុំរឿង Welke និង Bialek ទល់នឹង ប្រទេសប៉ូឡូញ* (ពាក្យសុំលេខ 15924/05), តុលាការសិទ្ធិមនុស្សអឺរ៉ុប, ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១១, ត្រង់កថាខណ្ឌ ៨៣ ។

[41] *សំណុំរឿង Welke និង Bialek ទល់នឹង ប្រទេសប៉ូឡូញ* (ពាក្យសុំលេខ 15924/05), តុលាការសិទ្ធិមនុស្សអឺរ៉ុប, ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១១, ត្រង់កថាខណ្ឌ ៨៤-៨៥ ។

[42] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤២ ។

[43] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤២ ។

[44] លោក Karnavas, *យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ: ការវិភាគស៊ីជម្រៅមួយលើស្ថាប័ន និងនីតិវិធី*, ជំពូកទី៨: ការប្រមូលភស្តុតាងនៅក្នុងសវនាការឧក្រិដ្ឋកម្មអន្តរជាតិ - ការយល់ឃើញរបស់មេធាវីការពារក្តី ដែលត្រូវបានកែតម្រូវដោយលោកចៅក្រម Michael Bohlander, Cameron ខែ ឧសភា ឆ្នាំ ២០០៧ ត្រង់ទំព័រ ៧៧ ។ អាចចូលមើលបាននៅ:

បង្ហាញពីទស្សនៈផ្ទុយគ្នាដូចនេះថា:

> អ្នកផ្សេងទៀត រួមមានដូចជាចៅក្រមអាមេរិកម្នាក់ឈ្មោះ Patricia M. Wald បង្ហាញពីទស្សនៈខុសគ្នា ហើយទស្សនៈមួយដែលមានទំនោរស្របទៅនឹងចេតនាដើមច្រើនជាង ទស្សនៈរបស់ស្ថាបនិកនានានៃសាលាក្តីអន្តរជាតិពិសេស ។ ដោយមានអសនៈនៅតុលាការ ICTY ចៅក្រម Wald បានកត់សម្គាល់ដូច្នេះ:
>
> 'ជាបឋម សាលាក្តីនានាត្រូវបានគេជំរុញឱ្យធ្វើសេចក្តីសន្និដ្ឋានលម្អិតអំពីទ្រឹស្តីសង្គម និងនយោបាយនៃព្រឹត្តិការណ៍ដែលនាំឱ្យមានអំពើឃោរឃៅដែលត្រូវការជំនុំជម្រះ ។... ទោះយ៉ាងណាក្តី ទាំងអ្នកវិភាគ ទាំងប្រជាពលរដ្ឋ និងមន្ត្រីនៃប្រទេសដែលចោទថាមានការជាប់ពាក់ព័ន្ធ បានធ្វើសំណូមពរកាន់តែច្រើនទៅៗថា ដំណើរការកាត់ក្តីទល់មុខគ្នា និងការរកឃើញរបស់ចៅក្រមប្រហែលជាមិនអាចញ៉ាំងឱ្យមានការប៉ាន់ប្រមាណល្អបំផុតចំពោះបញ្ហាប្រវត្តិសាស្ត្រឡើយ ។ លើសពីនេះទៀត 'ការវិនិច្ឆ័យទោស' ដោយតុលាការ ICTY ចំពោះអ្នកដែលបានចាប់ផ្តើម បានអូសបន្លាយ ឬបានបញ្ចប់សង្គ្រាមហើយ និងតើមូលហេតុអ្វីបានជាការកាត់ក្តីត្រូវស្ថិតនៅក្នុងបរិបទនីតិវិធីព្រហ្មទណ្ឌ ដោយគ្មានការរួមចំណែកពីរដ្ឋរបស់ខ្លួនផ្ទាល់ដែលជាមូលដ្ឋានគឺមិនយុត្តិធម៌ ឬយ៉ាងហោចណាស់ក៏ការកាត់ក្តីនោះមិនបានចូលចំណែកអ្វីដល់ការផ្សះផ្សានាពេលអនាគតដែរ'[45] ។

*ii. ច្បាប់ជាតិគាំទ្រការកោសលុបនៅពេលធ្វើចំណាត់ថ្នាក់ឯកសារសម្ងាត់ជាសាធារណៈ:*

៣៥. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា បទប្បញ្ញត្តិដែលបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេតពីច្បាប់ស៊ីវិលឡចេញពីប្រទេសមួយចំនួន ពោលគឺច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា បារាំង ស្វីស និង អាល្លឺម៉ង់ ពាក់ព័ន្ធនឹងការរំលោភលើការសម្ងាត់នៃការស៊ើបអង្កេត គឺសុទ្ធតែមិនផ្តល់

https://books.google.fr/books?id=6K9MHONs9KcC&printsec=frontcover&hl=fr&source=gbs_atb#v=onepage&q&f=false.

45 លោក Karnavas, *យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ: ការវិភាគស៊ីជម្រៅមួយលើស្ថាប័ន និងនីតិវិធី*, ជំពូកទី៨: ការប្រមូលភស្តុតាងនៅក្នុងសវនាការឧក្រិដ្ឋកម្មអន្តរជាតិ - ការយល់ឃើញរបស់មេធាវីការពារក្តី ដែលត្រូវបានកែតម្រូវដោយលោកចៅក្រម Michael Bohlander, Cameron ខែ ឧសភា ឆ្នាំ ២០០៧ ត្រង់ទំព័រ ៧៧-៧៨ ។ អាច ចូលមើលបាននៅ: https://books.google.fr/books?id=6K9MHONs9KcC&printsec=frontcover&hl=fr&source=gbs_atb#v=onepage&q&f=false.

ការគាំទ្រទាំងជំហររបស់អយ្យការ[46] និងក្រុមការពារក្ដី ។ ទោះជាយ៉ាងក្ដី ការអះអាងនេះមិនបានកោតសរសើរនូវចំណុចគោលរបស់ចៅក្រមស៊ើបអង្កេត ពោលគឺនៅពេលដែលពួកគាត់បានលើកឡើងថា ទាំងនេះគឺជាឧទាហរណ៍ដែលចង្អុលបង្ហាញពីលក្ខណៈធម្មតា នៃដីកាសម្រេចរងការជំទាស់៖ "បទប្បញ្ញត្តិស្រដៀងគ្នាទាក់ទងនឹងការចុះផ្សាយជាសាធារណៈមុនពេលជំនុំជម្រះក្ដី [ដូចបានអនុម័តនៅក្នុងសំណុំរឿងនេះ] ក៏មានចែងផងដែរនៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលឡូនៅប្រទេសផ្សេងទៀត ឧទាហរណ៍ដូចជាប្រទេសអាល្លឺម៉ង់ ស្វីស និងបារាំង ជាដើម"[47] ។

៣៦. លើសពីនេះ ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការដកស្រង់នូវមាត្រា ១៧៧-១ និងមាត្រា ២១២-២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ក៏ខ្លឹមសារមាត្រាទាំងនេះមានលក្ខណៈពាក់ព័ន្ធស្មើគ្នា ។ មាត្រាទាំងនេះអនុញ្ញាតឱ្យចៅក្រមស៊ើបអង្កេតចេញដីកាបង្គាប់ឱ្យចុះផ្សាយនូវសេចក្ដីសម្រេចរបស់តុលាការតែ*ជាផ្នែក* ឬទាំងស្រុង ឬការដាក់បញ្ចូលសេចក្ដីថ្លែងការណ៍មួយដែលជូនដំណឹងដល់សាធារណជនអំពីមូលដ្ឋាន និងលក្ខខណ្ឌនៃដីកាបង្គាប់ ឬដីកាសម្រេចនានានោះ[48] ។

---

[46] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៧-៥១ ។

[47] ដីកាសម្រេចរងការជំទាស់ ត្រង់កថាខណ្ឌ ១៦, ជើងទំព័រលេខ ២០ ។

[48] ក្រមព្រហ្មទណ្ឌនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៧-១ ដែលខ្លឹមសារដើមជាភាសាបាំរាំងចែងថា: ["Le juge d'instruction peut ordonner, sur la demande de la personne concernée ou, avec l'accord de cette personne, d'office ou à la demande du ministère public, soit la publication intégrale ou partielle de sa décision de non-lieu, soit l'insertion d'un communiqué informant le public des motifs et du dispositif de celle-ci, dans un ou plusieurs journaux, écrits périodiques ou services de communication au public par voie électronique qu'il désigne" ។ **ខ្លឹមសារបកប្រែក្រៅផ្លូវការ:** "តាមរយៈសំណើរបស់ជនដែលជាប់ពាក់ព័ន្ធ ឬតាមរយៈការព្រមព្រៀងរបស់គាត់ ឬតាមរយៈសំណើរបស់ព្រះរាជអាជ្ញាសាធារណៈ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យបោះពុម្ពផ្សាយនូវដីកាចោទប្រកាន់របស់គាត់ជាផ្នែកខ្លះៗ ឬទាំងស្រុង ឬការដាក់បញ្ចូលនៃសេចក្ដីថ្លែងការណ៍មួយ ដែលផ្ដល់ព័ត៌មានដល់សាធារណជនអំពីមូលដ្ឋាន និងការអនុម័តលក្ខខណ្ឌនានានៃដីកាចុះក្នុងកាសែតមួយ ឬច្រើន ដែលជាភ្នាក់ងារធ្វើការចុះផ្សាយតាមពេលកំណត់ជាទៀងទាត់ ឬជាការចុះផ្សាយតាមរយៈសេវាកម្មផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិកសាធារណៈដែលគាត់ជ្រើសរើស ។ កាលណាពេលវេលាអំណោយផល ចៅក្រមនឹងធ្វើការកំណត់ថាតើត្រូវដកស្រង់ផ្នែកណាខ្លះចេញពីសេចក្ដីសម្រេចដែលនឹងត្រូវធ្វើការបោះពុម្ពផ្សាយ ឬត្រូវកែតម្រូវពាក្យពេចន៍នៃសេចក្ដីថ្លែងការណ៍ដូចម្ដេចខ្លះ ដែលគាត់នឹងត្រូវដាក់បញ្ចូលក្នុងការផ្សព្វផ្សាយនោះ ។ ប្រសិនបើចៅក្រមមិនផ្ដល់តាមការស្នើសុំពីបុគ្គលពាក់ព័ន្ធណាមួយទេនោះ គាត់ត្រូវតែផ្ដល់សេចក្ដីសម្រេចមានសំអាងហេតុ ដែលអាចនឹងមានការប្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គចៅក្រមស៊ើបអង្កេត។"] ។ ក្រមព្រហ្មទណ្ឌនីតិវិធីព្រហ្មទណ្ឌបារាំងមាត្រា ២១២-១ ដែលខ្លឹមសារដើមជាភាសាបារាំងចែងថា៖ ["La chambre de l'instruction peut ordonner, sur la demande de la personne concernée, ou, avec l'accord de cette personne,

ការនេះអាចនឹងត្រូវបានធ្វើឡើង *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ឬតាមការស្នើសុំរបស់បុគ្គលពាក់ព័ន្ធ ឬតាមការស្នើសុំពីអយ្យការ[49] ។ ស្រដៀងគ្នានេះដែរ មានតែបទប្បញ្ញត្តិដាក់លាក់ពីរប៉ុណ្ណោះដែលស្ថិតនៅក្រោមច្បាប់អាល្លឺម៉ង់ ដាក់កាតព្វកិច្ចឱ្យមានការចុះផ្សាយទាំងស្រុងនូវសេចក្តីសម្រេចទាក់ទងនឹងការចេញនូវដីកាសម្រេចផ្តន្ទាទោស តែមិនមែនសម្រាប់ដីកាលើកលែងការចោទប្រកាន់ឡើយ[50] ។ នៅក្នុងប្រព័ន្ធដូចគ្នា ច្បាប់ប្រទេសស្វីសក៏បានបែងចែកនូវភាពខុសគ្នាចំពោះការចុះ

---

d'office ou à la demande du ministère public soit la publication intégrale ou partielle de l'arrêt de non-lieu, soit l'insertion d'un communiqué informant le public des motifs et du dispositif de celui-ci, dans un ou plusieurs journaux, écrits périodiques ou services de communication au public par voie électronique désignés par cette chambre" ។ **ខ្លឹមសារបកប្រែក្រៅផ្លូវការ:** "អង្គចៅក្រមស៊ើបអង្កេតអាចចេញសេចក្តីបង្គាប់តាមការស្នើសុំរបស់ជនពាក់ព័ន្ធណាម្នាក់ ឬតាមរយៈការយល់ព្រមរបស់បុគ្គលនោះចំពោះសំណើផ្ទាល់ខ្លួនរបស់គាត់ ឬតាមរយៈការស្នើសុំពីព្រះរាជអាជ្ញាសាធារណៈ ទោះជាការចេញផ្សាយនូវសេចក្តីលើកលែងទោសនោះត្រូវបានធ្វើឡើងជាផ្នែកខ្លះៗ ឬទាំងស្រុងក្តី ឬវាជាការបញ្ចូលនូវសេចក្តីថ្លែងការណ៍ដែលផ្តល់ព័ត៌មានដល់សាធារណជនអំពីមូលដ្ឋាន និងលក្ខខណ្ឌនៃសេចក្តីសម្រេចនៅក្នុងកាសែតមួយ ឬច្រើន ដែលជាភ្នាក់ងារធ្វើការបោះពុម្ពផ្សាយតាមពេលកំណត់ជាទៀងទាត់ ឬជាការចុះផ្សាយតាមរយៈសេវាកម្មផ្សព្វផ្សាយព័ត៌មានអេឡិចត្រូនិកសាធារណៈ ដែលត្រូវបានជ្រើសរើសដោយអង្គចៅក្រមស៊ើបអង្កេត ។ កាលណាពេលវេលាអំណោយផល ចៅក្រមជាអ្នកធ្វើការកំណត់ថាតើត្រូវដកស្រង់ផ្នែកណាខ្លះចេញពីសេចក្តីសម្រេចដែលនឹងត្រូវធ្វើការបោះពុម្ពផ្សាយ ឬធ្វើការជ្រើសរើសនូវពាក្យពេចន៍នៃសេចក្តីថ្លែងការណ៍ ដែលគាត់នឹងត្រូវដាក់បញ្ចូលក្នុងការចុះផ្សាយនោះ ។ ប្រសិនបើអង្គចៅក្រមស៊ើបអង្កេតមិនអនុញ្ញាតតាមសំណើរបស់ជនពាក់ព័ន្ធណាម្នាក់ទេនោះ ចៅក្រមត្រូវតែផ្តល់សេចក្តីសម្រេចមានសំអាងហេតុ។"] [ភ្ជាប់ជា**ឯកសារសំអាង ២**] ។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ១៧៧-១ និង មាត្រា ២១២-១ ។

[50] ក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ត្រង់ផ្នែកទី ១៦៥ (១) ដែលខ្លឹមសារដើមជាភាសាអាល្លឺម៉ង់ចែងថា: ["Ist die Tat nach § 164 öffentlich oder durch Verbreiten von Schriften (§ 11 Abs. 3) begangen und wird ihretwegen auf Strafe erkannt, so ist auf Antrag des Verletzten anzuordnen, daß die Verurteilung wegen falscher Verdächtigung auf Verlangen öffentlich bekanntgemacht wird." ។ **ខ្លឹមសារបកប្រែក្រៅផ្លូវការ:** "ប្រសិនបើបទល្មើសដែលមានចែងក្នុងមាត្រា១៦៤ ត្រូវបានប្រព្រឹត្តជាសាធារណៈ ឬតាមរយៈការផ្សព្វផ្សាយសម្ភារៈដែលបានសរសេរ (ត្រង់ផ្នែកទី១១ (៣)) ហើយបើសិនជាការផ្តន្ទាទោសត្រូវសម្រេចដាក់ទណ្ឌកម្ម តុលាការនឹងចេញសេចក្តីបង្គាប់ផ្អែកតាមពាក្យស្នើសុំរបស់ជនរងគ្រោះដែលទាមទារថា ការផ្តន្ទាទោសចំពោះការចោទប្រកាន់ខុស ត្រូវតែប្រកាសជាសាធារណៈ ។"] ។ ត្រង់ផ្នែកទី ២00(១) ដែលខ្លឹមសារដើមជាភាសាអាល្លឺម៉ង់ចែងថា: ["Ist die Beleidigung öffentlich oder durch Verbreiten von Schriften (§ 11 Abs. 3) begangen und wird ihretwegen auf Strafe erkannt, so ist auf Antrag des Verletzten oder eines sonst zum Strafantrag Berechtigten anzuordnen, daß die Verurteilung wegen der Beleidigung auf Verlangen öffentlich bekanntgemacht wird." ។ **បកប្រែក្រៅផ្លូវការ:** "ប្រសិនបើមានការធ្វើឱ្យអាម៉ាស់មុខត្រូវបានធ្វើឡើងជាសាធារណៈ ឬតាមរយៈការផ្សព្វផ្សាយសម្ភារៈដែលបានសរសេរ (ត្រង់ផ្នែកទី១១(៣)) ហើយបើការដាក់ពិន័យត្រូវបានសម្រេចអនុវត្តទោស តាមការស្នើសុំរបស់ជនរងគ្រោះ ឬបុគ្គលដែលមានសិទ្ធិក្នុងការដាក់

ផ្សាយដែលបានតម្រូវឱ្យធ្វើទាក់ទងនឹងដីកាលើកលែងការចោទប្រកាន់ដូច្នេះថា:

> ដីកាសម្រេចទាំងឡាយណាដែលមិនតម្រូវឱ្យទទួលយកដំណើការនីតិវិធី និងដីកាបង្គាប់ ទាំងឡាយដែលជាការសង្ខេបនូវទោសប្បញ្ញត្តិ ត្រូវបានចាត់ទុកថាជាដីកាដែលមិនតម្រូវឱ្យធ្វើការចុះផ្សាយឡើយ[51] ។

៣៧. ជារួមទៅ វាផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពោលគឺឧទាហរណ៍ប្រហាក់ប្រហែលគ្នាមួយចំនួនដែលទាញចេញពីប្រព័ន្ធច្បាប់ស៊ីវិល ឬការអនុវត្តស្រដៀងគ្នានឹងប្រព័ន្ធច្បាប់នេះ គាំទ្រនូវរបៀបកំណត់ចាត់ចែងដោយការប្រិតប្រៀង និងប្រយ័ត្នប្រយ៉ែងចំពោះដីកាសម្រេច ឬសាលក្រមនានាដែលមានភាពសម្ងាត់ ជាពិសេសសេចក្ដីសម្រេចទាំងឡាយណាដែលពាក់ព័ន្ធនឹងការលើកលែងបទចោទប្រកាន់ ។

*iii. ភាពសម្ងាត់នៃកិច្ចស៊ើបសួរមិនបានបង្អាក់ការអនុវត្តលើការបិទការកិច្ចស៊ើបសួរនោះទេ*

៣៨. សហព្រះរាជអាជ្ញាអន្តរជាតិក៏បានចោទប្រកាន់ផងដែរថាវិធាន៥៦ នៃវិធានផ្ទៃក្នុងមិនអាចអនុវត្តបានទេដោយសារតែកិច្ចស៊ើបសួរត្រូវបានបញ្ចប់[52] ។ ដើម្បីគាំទ្រដល់ការជំទាស់នេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា រាល់សេចក្ដីសម្រេចទាំងអស់របស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល និងគ្រប់ដំណើការនីតិវិធីជំនុំជម្រះទាំងអម្បាលម៉ានសុទ្ធតែត្រូវធ្វើជាសាធារណៈ ហើយនៅចុងបញ្ចប់នៃសំណុំរឿងនីមួយៗ ឯកសារសម្ងាត់ដែលនៅសល់ គឺត្រូវបានពិនិត្យសារឡើងវិញ ក្នុងបំណងធ្វើចំណាត់ថ្នាក់ឯកសារជាថ្មី[53] ។

---

ពាក្យស្នើសុំ នោះតុលាការនឹងចេញសេចក្ដីបង្គាប់ឱ្យមានការកាត់ទោសត្រូវប្រកាសជាសាធារណៈ ក្រោយការស្នើសុំ ។" [ភ្ជាប់ជា**ឯកសារសំអាង ៣**]។

[51] ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសស្វីស មាត្រា៨៨(៤) ចែងក្នុងភាសាដើមដែលមានខ្លឹមសារដូចតទៅ: ["Les ordonnances de classement et les ordonnances pénales sont réputées notifiées même en l'absence d'une publication."] *សូមមើលផងដែរ,* ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសស្វីស មាត្រា៨៨(៣) ចែងក្នុងភាសាដើមដែលមានខ្លឹមសារដូចតទៅ: ["Seul le dispositif des prononcés de clôture est publié." ។ **ខ្លឹមសារបកប្រែក្រៅផ្លូវការ:** "ក្នុងករណីមានសាលក្រមស្ថាពរ នោះមានតែសេចក្ដីសន្និដ្ឋាននៃសាលក្រមប៉ុណ្ណោះដែលត្រូវបានចុះផ្សាយ"] [ភ្ជាប់ជា**ឯកសារសំអាង ៤**] ។

[52] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២១-២៤ ។

[53] បណ្ដឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ២២ ។

៣៩. ប៉ុន្តែ វាជាករណីយុត្តិសាស្ត្រ "ដែលដំណាក់កាលស៊ើបសួរបានបញ្ចប់ជាផ្លូវការតែពេលណាដែលអង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ ដែលជំទាស់ដីកាដំណោះស្រាយតែប៉ុណ្ណោះ"[54] ។ លើសពីនេះ ការយោងរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះអង្គហេតុដែលថាឯកសារសម្ងាត់ត្រូវបានពិនិត្យសារជាថ្មីនៅចុងបញ្ចប់នៃសំណុំរឿងមួយ ក្នុងគោលបំណងដើម្បីធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ គឺជាការលើកឡើងដោយមានពិភាល់[55] ។ សហចៅក្រមស៊ើបអង្កេត*បាន*ពិនិត្យដីកាដំណោះស្រាយ (សំអាងហេតុ) ឡើងវិញ និងបានចេញសេចក្តីសម្រេចលើបញ្ហានេះ ។ ដោយសារការមើលឃើញក្នុងទិដ្ឋភាពដូច្នេះ ទើបបណ្តឹងឧទ្ធរណ៍ពុំមានអ្វីបង្ហាញពីការប៉ុនប៉ងចូលរួមក្នុង "វេទិកាទិញទំនិញ" តាមរយៈការស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិនិត្យមើលសារជាថ្មីលើបញ្ហាកំពុងចោទឡើងនេះ និងដាក់ចេញនូវទស្សនៈផ្ទាល់ខ្លួនបដិសេធការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ។

**គ. មានតែដីកាដែលមានលក្ខណៈជាការលើកលែងការចោទប្រកាន់តែប៉ុណ្ណោះ អនុញ្ញាតឱ្យមានការកោសលុបបច្ចុប្បន្ននេះបាន**

៤០. ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[56] សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយសមហេតុផលថា មានតែចរិតលក្ខណៈនៃដីកាដំណោះស្រាយដែលស្ថិតក្នុងទម្រង់ជាការលើកលែងការចោទប្រកាន់ប៉ុណ្ណោះ ដែលតម្រូវឱ្យមានការប្រើវិធីសាស្ត្រតឹងរ៉ឹងចំពោះការចុះផ្សាយជាសាធារណៈ ជាងការចុះផ្សាយនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

៤១. នៅក្នុងសេចក្តីប្រកាសព័ត៌មានមួយក្រោយពីការដាក់ចេញនូវដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) សហចៅក្រមស៊ើបអង្កេត បានថ្លែងថា:

*ដោយសារថា ដីកាដំណោះស្រាយមានលក្ខណៈជាការលើកលែងការចោទ*

---

54 ដីកាសម្រេចរងការចោទប្រកាន់ ត្រង់កថាខណ្ឌ ១៣ ។

55 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣១ ។

56 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៤-៤៥ ។

*ប្រកាន់* [ដូច្នេះ] សំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ និងដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវរក្សាទុកជាឯកសារសម្ងាត់ រហូតអង្គបុរេជំនុំជម្រះសម្រេចបដិសេធលើដីកាលើកលែងការចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះក្តី[57] ។

៤២. ក្រោយពីការចេញដីកាដំណោះស្រាយ (សំអាងហេតុ) សហចៅក្រមស៊ើបអង្កេតបានថ្លែងថា:

> ដោយសារមានការលើកលែងការចោទប្រកាន់ ក្រោមមូលហេតុថាមិនមានយុត្តាធិការគ្រប់គ្រាន់នោះ ទើប[អ្នកស្រី] អ៊ឹម ចែម នៅតែបន្តមានសិទ្ធិទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិឯកជនរបស់គាត់ដែលបណ្តាលឲ្យមានការរឹតត្បិតនូវព័ត៌មានមួយចំនួនដែលអាចផ្សព្វផ្សាយជាសាធារណៈ ហើយការរឹតត្បិតនេះ មានលក្ខណៈតឹងរ៉ឹង*ជាងករណីដែលបញ្ជូនគាត់ទៅជំនុំជម្រះ* ។ សិទ្ធិទាំងនេះអនុវត្តបានមែន ប៉ុន្តែនៅតែអាចបើកផ្លូវឲ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់អំពីការវិវត្តនៃកិច្ចដំណើរការនីតិវិធី[58] ។

៤៣. សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញឱ្យឃើញទេថា វិធីសាស្ត្រនេះមានវិការៈ កុំថាឡើយដល់ទៅថាសារណាទាំងនោះ បានឆ្លុះបញ្ចាំងឱ្យឃើញនូវការរំលោភបំពានឆន្ទានុសិទ្ធិ។ ការផ្អែកលើករណីយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងទៀត[59] គឺជាការធ្វើឡើងដោយមិនអើពើលើលក្ខណៈឆន្ទានុសិទ្ធិនៃដីកាសម្រេចរងការជំទាស់ ដែលជាសេចក្តីសម្រេចមានមូលដ្ឋានខុសគ្នារវាងវិធីសាស្ត្រនានាក្នុងដំណាក់កាលមុនពេលជំនុំជម្រះ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ និងវិធីសាស្ត្រអនុវត្តនៅ អ.វ.ត.ក ក៏ដូចជាលក្ខណៈវិសេសនៃដីកាលើកលែងការចោទប្រកាន់ ។

៤៤. ប្រសិនបើចាំបាច់ត្រូវតែធ្វើការយោងនូវករណីយុត្តិសាស្ត្រពីតុលាការអន្តរជាតិដទៃទៀត ការយោង

---

[57] 'សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម' ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39515 (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)។

[58] 'សហចៅក្រមស៊ើបអង្កេតដាក់ចេញដីកាសម្រេចមានសំអាងហេតុ ដោយធ្វើការលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤/១' ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39786 ។

[59] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៥-៣៩ ។

នោះ គ្រាន់តែធ្វើឡើងដើម្បីការបញ្ជាក់ពីករណីជាក់លាក់នៃការសម្រេចបែបនេះតែប៉ុណ្ណោះ[60] ។ គ្មានករណីយុត្តិសាស្ត្រណាមួយធ្វើឱ្យខិនថយដល់បញ្ហាជាប់ទាក់ទងនឹងភស្តុតាងជាក់ស្តែងពាក់ព័ន្ធនឹងសិទ្ធិក្នុងការទទួលបានការសន្មតថាគ្មានទោស ហើយនិងសិទ្ធិជនដែលអាចនឹងមានទំនាក់ទំនងកាន់តែរឹងមាំ នៅក្នុងកាលៈទេសៈនៃការលើកលែងការចោទប្រកាន់លើសំណុំរឿងមួយ ឬជាភាពចាំបាច់ក្នុងការធ្វើឱ្យមានតុល្យភាព ដែលអង្គជំនុំជម្រះនីមួយៗត្រូវតែធ្វើ៖ ពោលគឺការថ្លឹងថ្លែងឱ្យបានសមហេតុផលគ្រប់កាលៈទេសៈទាំងអស់ដើម្បីការពារនូវសិទ្ធិសំខាន់ៗទាំងនេះ[61] ។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានទទួលស្គាល់ដូច្នោះដែរ រាល់ដីកាសម្រេចទាំងឡាយណាដែលទាក់ទងនឹងការកោសលុប ដីកាសម្រេចនោះ ត្រូវតែធ្វើការ "វាយតម្លៃលើអង្គសេចក្តីម្តងមួយៗ តាមករណីជាក់ស្តែង" ក្នុងកាលៈទេសៈជាក់លាក់នោះ[62] ។ គ្មានទេវិធីសាស្ត្រដែលប្រើប្រាស់ "ទំហំមួយឱ្យត្រូវនឹងមាឌទាំងអស់" សម្រាប់ការកោសលុប ហើយក៏គ្មានវិធីសាស្ត្រណាមួយក្នុងបណ្តឹងឧទ្ធរណ៍ បង្ហាញឱ្យឃើញថាមានវិធានការសមហេតុផល និងសមាមាត្រ ដើម្បីការពារផលប្រយោជន៍យុត្តិធម៌ឡើយ ។

៤៥. ត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការអះអាងថា "ស្ទើតែព្យសនកម្មទៅនឹង

---

[60] ដីកាសម្រេចដែលរងការជំទាស់ ត្រង់កថាខណ្ឌ ១៥ ["ប្រព័ន្ធច្បាប់កំមិនឡូមានវិធីសាស្ត្រមិនសូវតឹងរ៉ឹងចំពោះសិទ្ធិជនរបស់ជនសង្ស័យ...វាមានភាពខុសគ្នាជាមួយនឹងវិធីសាស្ត្រតឹងរ៉ឹងជាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូដែលប្រើប្រាស់វិធីសាស្ត្រតឹងរ៉ឹងនេះ"] ។ ក្នុងន័យនេះ ក្រុមការពារក្តីកត់សម្គាល់ឃើញថាទាំងតុលាការ ICTY និង ICTR គឺជាតុលាការដែលមានប្រភពនីតិវិធីពីប្រព័ន្ធច្បាប់កំមិនឡូ ។ លើសពីនេះ វាខុសស្រឡះពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា តុលាការពិសេសសម្រាប់ប្រទេសលីបង់គឺជាតុលាការ "ផ្អែកលើគំរូច្បាប់ស៊ីវិលឡូ" (បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៤) តែការពិតទៅ "វិធាននៃកិច្ចដំណើរការនីតិវិធី និងភស្តុតាងនៃតុលាការនេះ រួមបញ្ចូលដោយច្បាប់កំមិនឡូ និងទំនៀមទម្លាប់ពីច្បាប់ស៊ីវិលឡូ" ។ (តុលាការពិសេសសម្រាប់ប្រទេសលីបង់ 'របាយការណ៍ប្រចាំឆ្នាំលើកទី ៧' (2015-2016) ទំព័រ ៦ [ភ្ជាប់ជា**ឯកសារសំអាង ៥**] ។

[61] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៣៥-៣៩ ។

[62] *សំណុំរឿងរបស់ The Prosecutor ទល់នឹង Thomas Lubanga Dyilo* (ICC-01/04-01/06-568), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាទៅនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ I ក្រោមចំណងជើងថា "សេចក្តីសម្រេចលើការបង្កើតគោលការណ៍ទូទៅការគ្រប់គ្រងលើការដាក់កម្រិតការបង្ហាញព័ត៌មានស្របតាមវិធាន៨១ (២) និង (៤) នៃ វិធាននីតិវិធី និងភស្តុតាង" ធ្វើនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ៣៦ និងត្រង់កថាខណ្ឌ ៣៩ [ភ្ជាប់ជា**ឯកសារសំអាង ៦**] ។

កេរ្តិ៍ឈ្មោះជាការខ្វាយខ្វល់សុពលមួយក៏ដោយ ក្នុងគោលបំណងដើម្បីវាយតម្លៃព្យសនកម្មមួយ... គេចាំបាច់ត្រូវតែពិចារណាពីឋានៈនៃកេរ្តិ៍ឈ្មោះរបស់បុគ្គល នៅមុនពេលការផ្សាយនោះ”[63] គឺជាការអះអាងខុសនឹងគោលការណ៍ និងជារឿងគ្រោះថ្នាក់មួយ ។

៤៦. ផ្ទុយទៅវិញ ដោយសារហេតុបច្ច័យកើតចេញពីនៃលក្ខណៈពិសេសនៃដីកាដំណោះស្រាយ *នេះ* សិទ្ធិក្នុងការមានជីវិតឯកជន និងកេរ្តិ៍ឈ្មោះ គឺនៅតែមាន និងមានហានិភ័យប្រឈម ព្រមទាំងត្រូវការឱ្យមានការការពារកាន់តែប្រសើរឡើងនៅក្នុងដំណាក់កាលនៃនីតិវិធីនេះ ។ បើកាលណាដីកាដំណោះស្រាយនាំឱ្យមានការបញ្ជូនទៅជំនុំជម្រះវិញ នោះការកាត់ក្តីជាសាធារណៈនឹងត្រូវយកមកអនុវត្ត ។ ដូចគ្នានេះដែរ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចបដិសេធចោលនូវដីកាដំណោះស្រាយ (សំអាងហេតុ) ហើយអ្នកស្រី អ៊ឹម ចែម ត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ដីកាដំណោះស្រាយ (សំអាងហេតុ) អាចត្រូវបានចាត់ជាចំណាត់ឯកសារសាធារណៈវិញ ទោះបីជាមានការកោសលុបខ្លះៗក្តី[64] ។ បញ្ហាមួយចំនួនដែលត្រូវបានកោសលុបក្នុងសំណៅបច្ចុប្បន្ន នឹងក្លាយជាបញ្ហាសម្ភារៈប្រើសម្រាប់ធ្វើការពិនិត្យពិច័យឱ្យមានតុល្យភាព ទាំងអំណះអំណាងដែលបានលើកឡើង ព្រមទាំងភស្តុតាងភ្ជាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីដែលការពិនិត្យនេះកើតឡើងនៅក្រៅបរិបទនៃការជំនុំជម្រះក្តីទល់មុខគ្នាមួយ នោះលទ្ធផលនៃការចុះផ្សាយមានទំហំធំធេង ដោយគ្មានលទ្ធផលល្អសម្រាប់បរិបទយុត្តិធម៌ និងភាពសមហេតុផល ក៏ដូចជាដំណើរការបន្តទៅមុខនៃនីតិវិធីតុលាការទេ ។ សំខាន់បំផុតគឺថា អ្នកស្រី អ៊ឹម ចែម នឹងត្រូវខកខានក្នុងការទទួលបាននូវឱកាសដ៏មានអត្ថន័យដើម្បីស្វះស្វែងឱ្យមានដីកាសម្រេចសមស្រប ដើម្បីធានាបាននូវការការពារសិទ្ធិរបស់អ្នកស្រីចំពោះការមានជីវិតឯកជន កេរ្តិ៍ឈ្មោះ និងសិទ្ធិទទួលបានការសន្មតថាគ្មានទោស[65] ។

៤៧. អាស្រ័យហេតុនេះហើយ សំអាងហេតុនៅក្នុងដីកាសម្រេចដែលរងការជំទាស់ជះឥទ្ធិពលលើភាព

---

[63] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៥ ។

[64] ‘សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម’ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39515 (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត) ។

[65] *សូមមើល,* ផ្នែកខាងក្រោម ត្រង់កថាខណ្ឌ ៤៨ ដល់ ៦១ ។

ចាំបាច់ក្នុងការការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ទាំងនោះ គឺជាការត្រឹមត្រូវ និងស្របតាមលក្ខណៈទៀងទាត់នៃដីកាលើកលែងការចោទប្រកាន់ និងលក្ខណៈពិសេសមួយចំនួននៃសំណុំរឿងនេះ[66] ។ លក្ខណៈពិសេសនៃសំណុំរឿងនេះនឹងត្រូវធ្វើការពិភាក្សាបន្ថែម នៅផ្នែកខាងក្រោម ត្រង់កថាខណ្ឌ ៤៨ ដល់ ៦៧ ។

## ឃ. ការកោសលុបពិចត្តួចនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) នឹងរំលោភលើសិទ្ធិអ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានជីវិតឯកជន និងការសន្មតថាគ្មានទោស

៤៨. នៅក្នុងសេចក្តីប្រកាសព័ត៌មាន ក្រោយពីការដាក់ចេញដីកាដំណោះស្រាយ (សំអាងហេតុ) សហចៅក្រមស៊ើបអង្កេតបានថ្លែងថា:

> ដោយសារមានការលើកលែងការចោទប្រកាន់ ក្រោមមូលហេតុថាមិនមានយុត្តាធិការគ្រប់គ្រាន់នោះ ទើប*[អ្នកស្រី] អ៊ឹម ចែម នៅតែបន្តមានសិទ្ធិទទួលបានការសន្មតថាគ្មានទោស និងសិទ្ធិឯកជនរបស់គាត់ដែលបណ្តាលឱ្យមានការរឹតត្បិតនូវព័ត៌មានមួយចំនួនដែលអាចផ្សព្វផ្សាយជាសាធារណៈ* ហើយការរឹតត្បិតនេះ មានលក្ខណៈតឹងរ៉ឹង*ជាងករណីដែលបញ្ជូនគាត់ទៅជំនុំជម្រះ* ។ សិទ្ធិទាំងនេះអនុវត្តបានមែន ប៉ុន្តែនៅតែអាចបើកផ្លូវឱ្យសាធារណជនទទួលបាននូវព័ត៌មានគ្រប់គ្រាន់អំពីការវិវត្តនៃកិច្ចដំណើរការនីតិវិធី[67] ។

៤៩. យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ដើម្បីធ្វើការថ្លឹងថ្លែងលើព្យសនកម្មដែលធ្វើឱ្យកេរ្តិ៍ឈ្មោះអ្នកស្រី អ៊ឹម ចែម ត្រូវបានរងផលប៉ះពាល់ដូចម្តេចនោះ គេចាំបាច់ត្រូវពិចារណាអំពីឋានៈនៃកេរ្តិ៍ឈ្មោះរបស់បុគ្គលម្នាក់នៅមុនពេលចេញផ្សាយ[68] ពោលគឺចំណាប់អារម្មណ៍ពីសំណាក់ប្រព័ន្ធផ្សព្វផ្សាយចំពោះបុគ្គលនោះ ។ សហព្រះរាជអាជ្ញាអន្តរជាតិបន្ថែមទៀតថា

---

[66] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៤៦ ។

[67] 'សហចៅក្រមស៊ើបអង្កេតដាក់ចេញដីកាសម្រេចមានសំអាងហេតុ ដោយធ្វើការលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤/១' ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39786 (សង្កត់ន័យបន្ថែមត្រង់ចំណុចអក្សរទ្រេត) ។

[68] បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥៥ ដល់ ៦២ ។

ការផ្តល់លទ្ធភាពឱ្យសាធារណជនអាចរកមើលបាន នូវអំណះអំណាងភ្ជាប់នឹងបទចោទប្រកាន់សំខាន់ៗដែលមាននៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការសន្មតថាគ្មានទោសនោះទេ ព្រោះការសន្មតថាគ្មានទោសមិនតម្រូវថាភស្តុតាងទាំងអស់ដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ គប្បីត្រូវរក្សាទុកជាព័ត៌មានអសាធារណៈឡើយ[69] ។

៥០. សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានលើកតម្កើងនូវទំហំនៃការពិចារណាលើបញ្ហាសិទ្ធិមនុស្សដែលបានធ្វើឡើង ក្នុងចេតនាសម្រាប់ការការពារសិទ្ធិកំពុងចោទ និងការថ្លឹងថ្លែងយ៉ាងប្រយ័ត្នប្រយ៉ែងពីសំណាក់សហចៅក្រមស៊ើបអង្កេត ។

៥១. មាត្រា ១៧ នៃ ICCPR ការពារប្រឆាំងនឹងការជ្រៀតជ្រែកតាមទំនើងចិត្តលើសិទ្ធិឯកជន និងការមានជីវភាពគ្រួសាររបស់បុគ្គលម្នាក់ៗ[70] ។ ដូចដែលបានទទួលស្គាល់ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្រាប់[71] និងដូចដែលត្រូវបានសម្រេចដោយអង្គបុរេជំនុំជម្រះ និងគណៈកម្មាធិការសិទ្ធិមនុស្សដូច្នោះដែរថា វិសាលភាពនៃការការពារដែលភ្ជាប់ជាមួយនឹងបម្រាមលើ "ការជ្រៀតជ្រែក ...តាមទំនើងចិត្ត" គឺជានិច្ចជាកាលអាស្រ័យលើអ្វីទៅដែលមានលក្ខណៈ*សមហេតុផល* តាមកាលៈទេសៈ[72] ។

៥២. សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យមាន*ភាពឧឡារិក*ក្នុងការកំណត់ពីទំហំនៃការដាក់បង្ហាញ និង/ឬ

---

69 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៥២ ដល់ ៥៨ ។

70 ICCPR ត្រង់មាត្រា១៧ ។

71 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ៦០ ។

72 *សំណុំរឿង មាស មុត* ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.៣១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [កោសលុប] ជំទាស់ដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលសុំដាក់បង្ហាញឯកសាររឿងក្តី ០០៣ នៅក្នុងរឿងក្តី ០០២ (ឯកសារ D100/25 និង D100/29 ) ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៧, ឯកសារ **D100/32/1/7** ត្រង់កថាខណ្ឌ ១៩ ។ យោបល់ទូទៅលេខ ១៦ លើមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស (HRC), HRI/GEN/1/Rev.9 (លេខ. I) (១៩៩៨) , ត្រង់កថាខណ្ឌ ៤ [ភ្ជាប់ជា**ឯកសារសំអាង ៧**] ។

ការកោសលុបព័ត៌មានចាំបាច់អ្វីខ្លះ និងថាតើការកោសលុបនោះ មានសមាមាត្រដែរឬទេ ដើម្បីការពារសិទ្ធិបុគ្គលឯកជន ព្រមទាំងបានសម្រេចដោយឆន្ទានុសិទ្ធិក្នុងការរឹតត្បិតលើការចុះផ្សាយនូវសេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់សំខាន់ៗ[73] ។

៥៣. ហានិភ័យនៃការកាត់សេចក្តីដោយប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានកើនឡើងខ្ពស់ជាលំដាប់នៅដំណាក់កាលនេះនៃសំណុំរឿងនេះ ។ ថ្វីបើវាការពិតក្តី ដែលបទចោទប្រកាន់ទាំងអស់ត្រូវបានទាត់ចោល ក៏ដីកាដំណោះស្រាយ (សំអាងហេតុ) សន្និដានថា អ្នកស្រី អ៊ឹម ចែម "អាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ" ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរទាំងនោះ[74] ។ ដូចមានចែងក្នុងមាត្រា ១៤ នៃ ICCPR សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាមទារឱ្យ "ប្រព័ន្ធផ្សព្វផ្សាយគប្បីត្រូវចៀសវាងនូវរាយការណ៍ព័ត៌មានដែលប៉ះពាល់ដល់ការសន្មតថាគ្មានទោស"[75] ។ ថ្វីបើតម្រូវការនេះ ត្រូវបានផ្តោតជាចម្បងទៅលើការប្រព្រឹត្តរបស់ប្រព័ន្ធផ្សព្វផ្សាយ ហើយមិនមែនជាសេចក្តីសម្រេចរបស់តុលាការក្តី ក៏ការចុះផ្សាយសាលក្រម អាចនឹងនាំឱ្យមានការរំលោភលើសិទ្ធិនេះដូចគ្នា ។ កាលៈទេសៈមួយចំនួនដែលកើតមាននៅ អ.វ.ត.ក វាស្ថិតក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិដ៏សមហេតុផលរបស់សហចៅក្រមស៊ើបអង្កេតក្នុងការសន្និដ្ឋានថា ការចេញផ្សាយទាំងស្រុងនូវដីកាដំណោះស្រាយ (សំអាងហេតុ) បានបង្កើតនូវហានិភ័យដែលមិនអាចទទួលយកបានដែលប្រព័ន្ធផ្សព្វផ្សាយធ្វើសេចក្តីរាយការណ៍ពីការសន្និដ្ឋានបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ដោយភ្ជាប់នឹងការទម្លាក់កំហុសលើរូបអ្នកស្រី អ៊ឹម ចែម ថាអ្នកស្រីមានទំនួលខុសត្រូវសំខាន់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយចំនួន គឺអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកស្រីក្នុងការទទួលបាននូវការសន្មតថាគ្មានទោស ។

៥៤. ពិតណាស់ បណ្តាញសារព័ត៌មានបានលាបពណ៌ទាក់ទាញចិត្តអ្នកអាន តាមរយៈការធ្វើនិទានកថា

---

[73] 'សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម' ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39515 ។

[74] ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ៣០៧ ។

[75] យោបល់ទូទៅលេខ ៣២ លើមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស (HRC), CCPR/C/GC/32 (២០០៧), ត្រង់កថាខណ្ឌ ៣០ [ភ្ជាប់ជា**ឯកសារសំអាង ៨**] ។

អំពីការជាប់ពាក់ព័ន្ធរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងសកម្មភាពឧក្រិដ្ឋ ផ្អែកលើមូលដ្ឋាននៃដីកាដំណោះស្រាយ (ផ្នែកសេចក្ដីសម្រេច) ដែលតាមរយៈការផ្អែកត្រឹមតែមូលដ្ឋានប៉ុណ្ណឹង បង្ហាញថាវាមិនទំនងនោះទេថាដីកាដំណោះស្រាយ (សំអាងហេតុ) មិនមានសេចក្ដីសន្និដ្ឋានទាក់ទងនឹងការភ្ជាប់អ្នកស្រី អ៊ឹម ចែម ទៅនឹងឧក្រិដ្ឋកម្មដែលអ្នកស្រីត្រូវបានចោទនោះ[76] ។

៥៥. ជាធម្មតា សេចក្ដីសន្និដ្ឋានបណ្ដោះអាសន្ន គឺងាយស្រួលនឹងយល់ច្រឡំ ឬអាចទំនងជាត្រូវបានយកទៅប្រើប្រាស់ខុស ។ សេចក្ដីសន្និដ្ឋានប្រភេទនេះ មិនមែនត្រឹមតែទំនងជាអាចទាក់ទាញឱ្យមានការរិះគន់មិនសមហេតុផល និងអយុត្តិធម៌ចំពោះ អ.វ.ត.ក ក្នុងនាមជាស្ថាប័នយុត្តិធម៌ចំពោះភាព 'បរាជ័យ' ក្នុងការទទួលខុសត្រូវលើឧក្រិដ្ឋធ្ងន់ធ្ងរនោះទេ ថែមទាំងជាការផ្ដល់នូវមូលដ្ឋានដែលកាន់តែបង្កឱ្យមានភាពគ្រោះថ្នាក់ និងការគុំកួនព្យាបាទថែមទៀតលើអ្នកស្រី អ៊ឹម ចែម ហើយនៅក្នុងករណីដែលការកំណត់សេចក្ដីសន្និដ្ឋានលើអង្គហេតុទាំងឡាយ ទំនងជាមិនត្រូវបានយកមកវែកញែកឡើយនៅក្នុងសវនាការសាធារណៈដូច្នេះ ។ ប្រការនេះ មិនមែនជាការអនុវត្តឆន្ទានុសិទ្ធិដ៏សមហេតុផលរបស់សហចៅក្រមស៊ើបអង្កេតនោះទេ នៅពេលពួកគាត់មិនយកចិត្តទុកដាក់លើហានិភ័យជាក់ស្ដែងទាំងនេះចំពោះសិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការសន្មតថាគ្មានទោស ។

៥៦. លើសពីនេះ ដូចដែលបានរៀបរាប់ខាងលើត្រង់កថាខ័ណ្ឌ៤០ ដល់ ៤៧ ហានិភ័យចំពោះសិទ្ធិទទួលបានការសន្មតថាគ្មានទោស គឺត្រូវបានលើកកម្ពស់នៅក្នុងកាលៈទេសៈដែលដីកាដំណោះស្រាយជា

---

[76] *សូមមើលជាឧទាហរណ៍,* ដោយៈ G Wright មានចំណងជើងថាៈ ការរួចពីនុយរបស់មន្ត្រីខ្មែរក្រហមដែលត្រូវបានសង្ស័យលើការសម្លាប់ក្នុងទ្រង់ទ្រាយធំ, កាសែត ខេមបូឌាដេលី ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧ ["ចៅក្រមស៊ើបអង្កេតកម្ពុជា លោក យូ ប៊ុនឡេង និងជាសហភាតាអន្តរជាតិរបស់គាត់ គឺលោក Michael Bohlander បានសម្រេចថាឧក្រិដ្ឋកម្មដែលអ្នកស្រី អ៊ឹម ចែម រងការចោទប្រកាន់ រួមបញ្ចូលទាំងការត្រួតត្រាលើការសម្លាប់ទ្រង់ទ្រាយធំនូវអ្នកទាំងឡាយណាដែលគេសង្ស័យថាជាជនក្បត់ គឺមិនត្រូវបានតុលាការចាត់ទុកថាមានសភាពធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបញ្ជូនទៅជំនុំជម្រះឡើយ...។ 'អ៊ឹម ចែម ត្រូវបានចោទថាបានទទួលបន្ទុកមើលការខុសត្រូវលើការសម្លាប់ប្រជាជនយ៉ាងច្រើនសន្ធឹកសន្ធាប់ បន្ទាប់ពីពួកគេត្រូវបានសង្ស័យថាមានចេតនាប្រឆាំងនឹងស្មារតីនៃរបបនេះ'... របាយការណ៍របស់[អង្គការឃ្លាំមើលសិទ្ធិមនុស្ស]បានឱ្យដឹងថា...កាលពីឆ្នាំ២០១៥ សែន សុផន បានផ្ដល់សក្ខីកម្មនៅពេលសវនាការ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី [នៃសំណុំរឿង ០០២] ដោយបាននិយាយថា អ៊ឹម ចែម...មើលទៅសហាវជាងអ្នកកាន់តំណែងមុនៗគាត់ទៅទៀតកាលពីគាត់មើលការខុសត្រូវនៅអាងត្រពាំងថ្ម"] [ភ្ជាប់ជា**ឯកសារសំអាង ៩**] ។

ដីកាសម្រេចច្រានចោលសំណុំរឿង ដោយសារលក្ខខណ្ឌនៃយុត្តាធិការបុគ្គល ។ មុនពេលក្រុមការពារក្ដីដាក់ចេញនូវចម្លើយតប ទៅនឹងសេចក្ដីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថា "បញ្ហាអង្គច្បាប់សំខាន់ៗ" ដែលត្រូវធ្វើការពិភាក្សានៅក្នុងដីកាដំណោះស្រាយ គឺបញ្ហាយុត្តាធិការបុគ្គល[77] ។ ជនសង្ស័យបានពឹងផ្អែកលើសេចក្ដីជូនដំណឹងនេះ ដោយកម្រិតការឆ្លើយតបរបស់អ្នកស្រីត្រឹមបញ្ហានេះ ។

៥៧. បើទោះបីជាមានការគូសបញ្ជាក់ខាងលើក្ដី ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រូវបានដាក់ចេញជាសេចក្ដីសន្និដ្ឋាន *បណ្ដោះអាសន្ន* ទាក់ទងនឹងការទម្លាក់កំហុសផ្នែកព្រហ្មទណ្ឌលើអ្នកស្រី អ៊ឹម ចែម[78] ។ ដោយទុកមួយឡែកនូវការលើកឡើងពីការធ្វើ *ហួសពីដែនអំណាចច្បាប់* កម្មវត្ថុ និងគោលបំណងនៃដីកាដំណោះស្រាយ (ដូចដែលបានពិភាក្សាខាងក្រោមនៅកថាខណ្ឌ ៦២ ដល់ ៦៧) ទើបក្រុមការពារក្ដី ត្រូវបានដកហូតនូវឱកាសដ៏មានអត្ថន័យដើម្បីធ្វើការឆ្លើយតបចំពោះការចោទប្រកាន់សំខាន់ៗ ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម លើផ្នែកព្រហ្មទណ្ឌដែលអ្នកស្រីត្រូវបានរងការចោទប្រកាន់ ក៏ដូចជាការត្រូវឆ្លើយតបទៅនឹងការសន្និដ្ឋានបណ្ដោះអាសន្នទាំងនេះ ។ ដូចដែលបានពិភាក្សាខាងលើនៅកថាខណ្ឌ ៤០ ដល់ ៤៧ រួចហើយ ប្រសិនបើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានអនុញ្ញាត អ្នកស្រី អ៊ឹម ចែម នឹងត្រូវបានដកហូតនូវឱកាសដ៏មានអត្ថន័យដើម្បីធ្វើការឆ្លើយតប ឬធ្វើការតតាំងនឹងភស្តុតាងទាំងឡាយដែលកំណត់នៅក្នុងអំណះអំណាងទាំងនេះ បើទោះជាការសន្និដ្ឋានមានវិវាទនោះ ក្លាយជាបញ្ហាកំណត់ត្រាសាធារណៈ និងការសន្មតទុកដោយប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ។

៥៨. នៅក្នុងកាលៈទេសៈទាំងនេះ រាល់ការរំលោភលើការសន្មតថាគ្មានទោសនឹងមានភាពធ្ងន់ធ្ងរ និងមិនអាចត្រឡប់រកសភាពដើមវិញបានឡើយ ។ អ្នកស្រី អ៊ឹម ចែម នឹងមិនមានឱកាសក្នុងការបដិសេធទៅនឹងការរកឃើញរបស់តុលាការ ដែលទម្លាក់កំហុសលើអ្នកស្រី ថាបានជាប់ពាក់ព័ន្ធនឹង

---

77 សេចក្ដីជូនដំណឹងមេធាវីការពារក្ដី អំពីកាលបរិច្ឆេទកំណត់ក្នុងការឆ្លើយតបទៅនឹងដីកាសន្និដ្ឋាន[ស្ថាពរ] តាមវិធាន ៦៦(៥) របស់សហព្រះរាជអាជ្ញា ធ្វើនៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ **D304/4** ត្រង់កថាខណ្ឌ ៦ ។

78 ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ៣០៦ ដល់ ៣១១ ។

សកម្មភាពឧក្រិដ្ឋ ឬមានឱកាសធ្វើការតតាំងនឹងភស្តុតាងគាំទ្រដល់ការរកឃើញបែបនេះឱ្យបាន ត្រឹមត្រូវ ឬធ្វើការដាក់បង្ហាញដល់សាធារណជន បន្សល់ទុកនូវភាពខ្មោងងឹតនៃភាពលម្អៀង និង មានលក្ខណៈបញ្ឆិតបញ្ឆៀង ។ ប្រការនេះ មិនមែនសមស្របតែទៅនឹងសិទ្ធិរបស់អ្នកស្រី អ៊ីម ចែម ដែលត្រូវបានសន្មតថាគ្មានទោសនោះទេ ប៉ុន្តែថែមទាំងសិទ្ធិទទួលបានការជំនុំជម្រះដោយ យុត្តិធម៌របស់អ្នកស្រីផងដែរ ជាពិសេស សិទ្ធិធ្វើការពិនិត្យលើភស្តុតាងប្រឆាំងខ្លួន និងសិទ្ធិក្នុងការ ពិនិត្យឡើងវិញនូវដីកាសម្រេចអវិជ្ជមាននានា[79] ។

៥៩. លើសពីនេះ ផលប៉ះពាល់បែបនេះ នឹងប៉ះពាល់ដល់សិទ្ធិឯកជនរបស់អ្នកស្រី អ៊ីម ចែម ។ នៅ ក្នុងសំណុំរឿង *Sayadi និង Vinck ទល់នឹងប្រទេស Belgium* គណៈកម្មាធិការសិទ្ធិមនុស្សបាន លើកឡើងថាមាត្រា១៧ នៃ ICCPR រួមបញ្ចូលការការពារនូវ "ការផ្សំគំនិតអវិជ្ជមាន" ដែលអាច កើតឡើងពីការបោះពុម្ពផ្សាយនូវព័ត៌មាន ដោយភ្ជាប់ជនណាម្នាក់ទៅនឹងសំណុំរឿងព្រហ្មទណ្ឌ ក្រោយពេលជននោះ ត្រូវបានទទួលបានការលើកលែងហើយ[80] ។ ទោះបីជាការបោះពុម្ពផ្សាយ ព័ត៌មានក្នុងករណីនេះ ត្រូវបានបញ្ចេញដោយរដ្ឋក៏ដោយ កាលណាវាផុយពីអំណាចតុលាការ គណៈកម្មាធិការសិទ្ធិមនុស្សបានចាត់ទុកថាវាជា "ការផ្សំគំនិតអវិជ្ជមាន" ដែលអាចត្រូវបានដក យកចេញពីព័ត៌មានដែលបានបោះពុម្ពផ្សាយរួចហើយ (បង្ហាញពីការចូលរួមផ្សំគំនិតរបស់អ្នកនិពន្ធ ជាមួយនឹងសកម្មភាពឧក្រិដ្ឋ) បូករួមជាមួយនឹងការទទួលស្គាល់ថា ទង្វើនេះបាននាំឱ្យមានការ "បោះពុម្ពផ្សាយអត្ថបទសារព័ត៌មានជាច្រើន ដែលធ្វើឱ្យមានការសង្ស័យលើកេរ្តិ៍ឈ្មោះរបស់អ្នក និពន្ធ" មានន័យថា សិទ្ធិមានជីវិតឯកជនគាត់ គឺត្រូវបានគេរំលោភបំពាន[81] ។

៦០. លើសពីនេះ ការបោះពុម្ពផ្សាយដីកាដំណោះស្រាយដែលមានលក្ខណៈជាការលើកលែងការចោទ ប្រកាន់ គឺសំដៅកាត់បន្ថយចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយក្នុងកិច្ចស៊ើបអង្កេតតាមរយៈ

---

[79] ICCPR ត្រង់មាត្រា ១៤(៣)(ង) និងមាត្រា ១៤(៥) ។

[80] សំណុំរឿង *Sayadi* និង *Vinck* ទល់នឹងប្រទេស *Belgium*, ធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស (HRC), CCPR/C/94/D/1472/2006 (២០០៨), ត្រង់កថាខណ្ឌ ១០.១២-១៣ [ភ្ជាប់ជា**ឯកសារសំអាង ១០**] ។

[81] សំណុំរឿង *Sayadi* និង *Vinck* ទល់នឹងប្រទេស *Belgium*, ធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស (HRC), CCPR/C/94/D/1472/2006 (២០០៨), ត្រង់កថាខណ្ឌ ១០.១២-១៣ ។

ការផ្តល់ព័ត៌មាន*ចាំបាច់*ដែលពន្យល់ពីហេតុផលអ្វី នាំឱ្យមានការច្រានចោលនូវសំណុំរឿងនេះ[82] ។ សំណៅព័ត៌មានកោសលុបដែលទាក់ទងពីទិដ្ឋភាពនៃសំណុំរឿង គឺមិនមានភាពចាំបាច់សម្រាប់ឱ្យយល់ដឹងទាំងស្រុងនូវផ្នែកសេចក្តីសម្រេចនោះទេ ហើយវាក៏បានបម្រើដល់ផលប្រយោជន៍យុត្តិធម៌ដែរ ចំពោះការដាក់បង្ហាញព័ត៌មានទាំងនេះ ។ ជំនួសមកវិញ ដូចបានពិភាក្សាបន្ថែមខាងក្រោមនៅកថាខណ្ឌ ៦២ ដល់ ៦៧ ដោយសារសេចក្តីសម្រេចច្រានចោលបទចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ត្រូវបានពឹងផ្អែកទាំងស្រុងលើបញ្ហាយុត្តាធិការ ហើយបញ្ជីរឿងរ៉ាវនៃដីកាដំណោះស្រាយក៏ត្រូវបានផ្អែកលើអំណាចច្បាប់ដែលសហចៅក្រមស៊ើបអង្កេតមាន ក្នុងការពិចារណាលើធាតុសំខាន់ៗនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដូច្នេះគ្មានហេតុផលប្រឆាំងនឹងទស្សនៈសិទ្ធិមនុស្សណាមួយ តម្រូវឱ្យមានការចុះផ្សាយសេចក្តីសន្និដ្ឋាននូវធាតុសំខាន់ៗទាំងនេះជាសាធារណៈនោះទេ ។ ផ្ទុយទៅវិញ ការបោះពុម្ពផ្សាយសេចក្តីសន្និដ្ឋាន*ហួសពីអំណាចច្បាប់*ដែលបានរៀបរាប់ខាងលើ ឬសេចក្តីសន្និដ្ឋានដែលជាប់ទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋ គឺជាការមិនផ្តល់នូវការបំភ្លឺអ្វីមួយដល់ផ្នែកសម្រេចសេចក្តីទេ ប៉ុន្តែនឹងលើកទឹកចិត្តឱ្យប្រព័ន្ធផ្សព្វផ្សាយរាយការណ៍លើរឿងរ៉ាវសំខាន់ៗ ដែលជាការបង្កឱ្យមានការផ្សំគំនិតអវិជ្ជមាន ដែលអាចនឹងមិនត្រូវបានទទួលការការពារ ឬពន្យល់ឱ្យបានគ្រប់គ្រាន់ឡើយ ។

៦១. ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយសមហេតុផលថា ការកោសលុប គឺធ្វើ

---

[82] *សូមមើល*, អត្ថបទរបស់ J-Y Lassalle, 'Affichage ou diffusion de la décision', *Répertoire de droit pénal et de procédure pénale*, ធ្វើនៅខែមីនា ឆ្នាំ ២០១៦ ត្រង់កថាខណ្ឌ ៤៣ ដែលមានពាក្យពេចន៍ដើមដូចតទៅ: [« L'objectif [des dispositions des articles 177-1 et 212-1 du Code de Procédure Pénale] vise à atténuer les impacts médiatiques que peuvent avoir les enquêtes et les instructions relatées dans la presse écrite ou audiovisuelle, en informant les lecteurs, auditeurs ou spectateurs que telle affaire, portée précédemment à leur connaissance, a finalement abouti à un non-lieu. » ។ **ខ្លឹមសារបកប្រែក្រៅផ្លូវការ:** "គោលដៅនៃ [មាត្រា ១៧៧-១ និង ២១២-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ] មានបំណងបន្ថយចំណាប់អារម្មណ៍របស់ប្រព័ន្ធផ្សព្វផ្សាយ ដែលកិច្ចស៊ើបអង្កេតដែលបានកត់ត្រានៅក្នុងកាសែតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយដោយផ្តល់ដំណឹងដល់អ្នកអាន អ្នកស្តាប់ និងអ្នកតាមដានព័ត៌មានដឹងថា សំណុំរឿងនេះ ដែលពួកគេបានដឹងឮបានឈានដល់ដំណាក់កាលទម្លាក់ចោលបទនូវការចោទប្រកាន់" [ភ្ជាប់ជា**ឯកសារសំអាង ១១**] ។

ឡើងដើម្បីការពារផលប្រយោជន៍យុត្តិធម៌ រួមទាំងភាពចាំបាច់ និងសិទ្ធិសំខាន់ៗទាំងនេះ[83] ។ នៅក្នុងកាលៈទេសៈទាំងនេះ ការកោសលុបបច្ចុប្បន្នកើតចេញពីការខ្វះខ្នែងធ្វើឱ្យមានតុល្យភាពសមស្របរវាងសិទ្ធិរបស់សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយក្នុងការទទួលបានព័ត៌មាន ទល់នឹងសិទ្ធិមានជីវិតឯកជនរបស់អ្នកស្រី អ៊ឹម ចែម ព្រមទាំងការត្រូវបានសន្មតថាគ្មានទោស ។

**ង. សេចក្តីសន្និដ្ឋាន *ហួសពីអំណាចច្បាប់* ទាំងអស់នៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) គួរតែរក្សាទុកការកោសលុបឱ្យនៅដដែល**

៦២. សហព្រះរាជអាជ្ញាអន្តរជាតិបានតវ៉ាថា ការចេញសេចក្តីថ្លែងការណ៍របស់ក្រុមការពារក្តីបន្ទាប់ពីការទម្លាក់ចោលបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម បានធ្វើឱ្យសាធារណជនយល់ច្រឡំដោយការថ្លែងថាដីកាដំណោះស្រាយ (សំអាងហេតុ) បានចង្អុលបង្ហាញថាអ្នកស្រី "ជនស្លូតត្រង់" ខណៈដែលការពិតទៅ សហចៅក្រមស៊ើបអង្កេតបានរកឃើញថាអ្នកស្រី អ៊ឹម ចែម បានចូលរួមក្នុងមធ្យោបាយជាច្រើនលើឧក្រិដ្ឋកម្មដ៏សែនធ្ងន់ធ្ងរទាំងនោះ[84]។

៦៣. ក្រុមការពារក្តីយល់ឃើញថា អំណះអំណាងទាំងអស់ទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកស្រី អ៊ឹម ចែម នៅក្នុងបទល្មើសព្រហ្មទណ្ឌដូចត្រូវបានចោទចំពោះឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងរឿងក្តីនេះ គឺជាបញ្ហាដែលសហចៅក្រមស៊ើបអង្កេតមិនមានសមត្ថកិច្ចដោះស្រាយ ហេតុដូច្នេះ វាគឺជាបញ្ហា *ហួសពីអំណាចច្បាប់* ។

៦៤. ក្រុមការពារក្តីយល់ថា កាតព្វកិច្ចបឋមរបស់តុលាការ គឺត្រូវបញ្ជាក់ពីសមត្ថកិច្ចរបស់ខ្លួនសិន[85] ។

---

83 'សហចៅក្រមស៊ើបអង្កេតដាក់ចេញដីកាសម្រេចមានសំអាងហេតុ ដោយធ្វើការលើកលែងការចោទប្រកាន់លើសំណុំរឿង ០០៤/១' ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧, អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39786 ។

84 បណ្តឹងឧទ្ធរណ៍ ត្រង់កថាខណ្ឌ ១៧ ។

85 *សូមមើល*, សាលក្រមរបស់តុលាការរដ្ឋបាលនៃអង្គការពលកម្មអន្តរជាតិលើពាក្យបណ្តឹងដែលបានធ្វើឡើងប្រឆាំងអង្គការអប់រំសង្គម និងវប្បធម៌របស់អង្គការសហប្រជាជាតិ (IC.J. របាយការណ៍ឆ្នាំ ១៩៥៦) មតិយោបល់ណែនាំ ធ្វើនៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៥៦ ។ មតិយោបល់ផ្សេងគ្នារបស់ចៅក្រម Cordova ត្រង់ទំព័រ ១៦៣ [ភ្ជាប់ជា**ឯកសារសំអាង ១២**] ដោយបានដកស្រង់ចេញពីសំណុំរឿងរបស់ *រដ្ឋអាជ្ញា ទល់នឹង Dusko Tadić* (IT-94-1), ដីការបស់សាលាឧទ្ធរណ៍, ដីកាសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំឱ្យទទួលយកបណ្តឹងឧទ្ធរណ៍លើបញ្ហាដែនសមត្ថកិច្ចតុលាការ ធ្វើនៅថ្ងៃទី

ភាពជាម្ចាស់យុត្តាធិការរបស់តុលាការ គឺធ្វើការកំណត់នូវសិទ្ធិអំណាចរបស់ស្ថាប័នតុលាការដើម្បី បង្កើតនូវអំណះអំណាងផ្លូវច្បាប់ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលម្នាក់ ។ ជាក់ស្តែង អំណះអំណាងបង្ហាញពីកង្វះយុត្តាធិការ គឺស្មើនឹងការខ្វះអំណាចស្របច្បាប់ដើម្បីធ្វើការសម្រេច តាមផ្លូវតុលាការលើសុពលភាពនៃសំណុំរឿងនេះ ។ ក្នុងន័យនេះ សេចក្តីសន្និដ្ឋានរបស់តុលាការ លើខ្លឹមសារសំខាន់ៗនៃឧក្រិដ្ឋកម្ម ឬការទទួលខុសត្រូវលើបទល្មើសព្រហ្មទណ្ឌរបស់ជនសង្ស័យ ដែលបានរងការចោទប្រកាន់ដោយគ្មានយុត្តាធិការ គឺការធ្វើឡើងនៅ*ចំពោះមុខជនដែលមិនមែនជា ចៅក្រម*[86] ។

៦៥. នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា:

> ៣៤. ...នៅដំណាក់កាលណាមួយនៃកិច្ចដំណាក់កាលនីតិវិធី ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូងបានដឹងថា ខ្លួនប្រហែលជាខ្លួនកំពុងអនុវត្តហួសពីយុត្តា ធិការរបស់ខ្លួន ពេលនោះអង្គជំនុំជម្រះត្រូវតែពិនិត្យពិចារណាអំពីបញ្ហានេះ ។

---

២ ខែ តុលា ឆ្នាំ ១៩៩៥ ត្រង់កថាខណ្ឌ ១៨ [ភ្ជាប់ជា**ឯកសារសំអាង ១៣**] ។ *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Milan Milutinović និងអ្នកផ្សេងទៀត* (IT-05-87-PT), សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, សេចក្តីសម្រេចលើញត្តិ ស្តីពីបញ្ហាយុត្តាធិការរបស់ Ojdanic: សហចារីដោយប្រយោល, ថ្ងៃទី២២ ខែ មីនា ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ២៤, ៤០ [**ខ្លឹមសារនៃសារណាត្រង់កថាខណ្ឌ៤០**៖ ["អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាទម្រង់ នៃការទទួលខុសត្រូវដែលមាន ចែងក្នុងកថាខណ្ឌ២២ នៃសំណួមពររួមពីអ្នកសុំធ្វើវិសោធនកម្មលើបទចោទប្រកាន់ គឺមិនមាននៅក្នុងច្បាប់អន្តរជាតិទំនៀម ទម្លាប់នោះទេ នៅពេលដែលកើតមានព្រឹត្តិការណ៍ដែលត្រូវបានរងការចោទនៅក្នុងដីកាចោទប្រកាន់ ។ អង្គជំនុំជម្រះបាន រម្លឹកឡើងវិញនូវសេចក្តីសង្កេតរបស់ខ្លួននៅក្នុងកថាខណ្ឌ២៥ផ្នែកខាងលើថា ប្រសិនបើលក្ខខណ្ឌទាំងពីរដែលបានមកពីអង្គ ជំនុំជម្រះសាលាឧទ្ធរណ៍កាលពីខែឧសភា ឆ្នាំ ២០០៣ នោះ សេចក្តីសម្រេចរបស់ *Ojdanic* គឺមិនត្រូវបានបំពេញតាម ទម្លាប់នៃការទទួលខុសត្រូវទេនោះ តុលាការក៏គ្មានយុត្តាធិការដើម្បីកំណត់ពីទោសកំហុសរបស់ជនជាប់ចោទអនុលោមតាម ទម្រង់នោះដែរ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងមិនចូលរួមក្នុងការពិនិត្យមើលថាតើលក្ខន្តិកៈមានលក្ខណៈទូលំ ទូលាយគ្រប់គ្រាន់ឬទេ ដើម្បីរួមបញ្ចូល "សហចារីដោយប្រយោល" ប្រសិនបើទម្រង់នៃការទទួលខុសត្រូវបែបនេះ មិនមាន នៅក្នុងទំនៀមទម្លាប់។"] (លុបចោលសេចក្តីយោង) [ភ្ជាប់ជា**ឯកសារសំអាង ១៤**] ។

[86] "ចំពោះមុខបុគ្គលដែលមិនមែនជាចៅក្រម," "ដោយគ្មានយុត្តាធិកា" ។ *សូមមើលផងដែរ*, E. Widder, ការជំនុំជម្រះដោយ យុត្តិធម៌នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ? បទដ្ឋានស្តីពីសិទ្ធិមនុស្ស និងភាពស្របច្បាប់ (Peter Lang, ២០១៦), ត្រង់ទំព័រ ២១៧ ["ការស្វែងរកការពិត ជានិច្ចជាកាលត្រូវតែបានគាំទ្រដោយអំណាចស្របច្បាប់ដើម្បីចេញនូវសេចក្តីសម្រេចមួយ ទៅបាន"] ។

តុលាការដែលមានសមត្ថកិច្ច គឺជាបុរេលក្ខខណ្ឌនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។ ការបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានយុត្តាធិការ នឹងធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋាននៃអាណត្តិរបស់ អ.វ.ត.ក និងធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងលែងមានអំណាចស្របច្បាប់ដើម្បីជំនុំជម្រះជនជាប់ចោទ ។

៣៥. ...ទោះបីជាមិនមានភាគីណាមួយលើកឡើងនូវការជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៅតែមានកាតព្វកិច្ចធានាថា ខ្លួនពិតជាមានយុត្តាធិការលើរឿងក្តីនៅចំពោះមុខខ្លួន ទើបខ្លួនអាចចេញសាលក្រមលើអង្គសេចក្តីបាន[87] ។

៦៦. ការពិតដែលថាយុត្តាធិការបង្កើតបានជាបុរេលក្ខខណ្ឌចាំបាច់មួយ ដើម្បីអាចរកឃើញនូវដើមចមនៃអង្គសេចក្តីនានាដែលកើតចេញមកពីចរិកលក្ខណៈនៃយុត្តាធិការ ។ បើគ្មានយុត្តាធិការសម្រាប់សំណុំរឿងជាក់លាក់ណាមួយទេនោះ តុលាការ “មិនអាចផ្តល់អំណះអំណាងអ្វីមួយ ឬក៏អាចធ្វើសេចក្តីសង្កេតអ្វីក៏ដោយ” នៅលើខ្លឹមសារសំខាន់ៗនៃសំណុំរឿងនោះឡើយ[88] ។ ហេតុដូច្នេះ ការ

---

[87] សំណុំរឿង០០១ សាលដីកាលើបណ្តឹងសារទុក្ខ, ឯកសារ **F28** ត្រង់កថាខណ្ឌ ៣៤-៣៥ ។

[88] *សំណុំរឿងពាក់ព័ន្ធនឹងការប្រើកម្លាំងតាមផ្លូវច្បាប់ (Serbia និង Montenegro ទល់នឹងប្រទេស Belgium)*, (របាយការណ៍របស់ I.C.J. ឆ្នាំ ២០០៤) សាលដីកាលើការជំទាស់បឋម ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤, ត្រង់កថាខណ្ឌ ១២៨ [“ទោះយ៉ាងណាក្តី សម្រាប់សំណុំរឿងបច្ចុប្បន្ន កាលណាតុលាការឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនគ្មានដែនសមត្ថកិច្ចដើម្បីចាត់ការលើការអះអាងដែលមាននៅក្នុងពាក្យស្នើសុំហើយនោះ”] ខ្លួនក៏មិនអាចធ្វើសេចក្តីសន្និដ្ឋាន ឬធ្វើការសង្កេតលើបញ្ហាអ្វីក៏ដោយ ទាក់ទងនឹងសំណួរចោទស្តីពីថាតើការរំលោភបំពានត្រូវបានប្រព្រឹត្តទៅដោយរបៀបណា ឬការទទួលខុសត្រូវជាអន្តរជាតិអ្វីខ្លះដែលកើតឡើង ។ [ភ្ជាប់ជា**ឯកសារសំអាង ១៥**]”] ។ *សំណុំរឿងពាក់ពន្ធ័នឹងប្រទេសទីម័រខាងកើត (រវាងប្រទេសព័រទុយហ្គាល់ ទល់នឹង ប្រទេសអូស្ត្រាលី)*, (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៩៥) សាលដីកាចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ត្រង់កថាខណ្ឌ ៣៥-៣៦ [កថាខណ្ឌ ៣៦៖ ដោយបានច្រានចោល នូវការជំទាស់លើកទីមួយក្នុងចំណោមពីរ របស់ប្រទេសអូស្ត្រាលីដែលការជំទាស់នេះត្រូវបានពិនិត្យវិនិច្ឆ័យប៉ុន្តែបានសម្រេចទទួលយកជំទាស់លើកទីពីរ [ការជំទាស់លើបញ្ហាយុត្តាធិកា] តុលាការយល់ឃើញថា... តុលាការមិនអាចចេញសេចក្តីសម្រេចលើពាក្យបណ្តឹងរបស់ប្រទេសព័រទុយហ្គាល់បានទេ ទាំងសុពលភាពនៃអង្គសេចក្តីទោះបីមានសំណួរចោទឡើងសំខាន់យ៉ាងណាក៏ដោយ ទាំងការបរិយាយនូវអំណះអំណាងដោយម្ចាស់ពាក្យបណ្តឹង ព្រមទាំងការលើកឡើងវិធានច្បាប់អន្តរជាតិពាក់ព័ន្ធ”] [ភ្ជាប់ជា**ឯកសារសំអាង ១៦**] ។ *សំណុំរឿងទាក់ទងនឹងសកម្មភាពប្រដាប់អាវុធនៅលើទឹកដីកុងហ្គោ (ពាក្យសុំថ្មី នៅឆ្នាំ ២០០២) (សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោរ៍ ទល់នឹង ប្រទេសរវ៉ាន់ដា)* (របាយការណ៍របស់ I.C.J. ឆ្នាំ ២០០៦) សាលដីកាលើយុត្តាធិការរបស់តុលាការ និងការទទួលយកពាក្យសុំ, ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៦, ត្រង់កថាខណ្ឌ ១២៧

បង្កើតយុត្តាធិការ គឺជាការចាំបាច់ដែលមិនអាចខ្វះបាន ដើម្បីឱ្យតុលាការធ្វើការសម្រេចសេចក្តីលើខ្លឹមសារសំខាន់ៗនៃសំណុំរឿងកំពុងចោទឡើងនេះ។ និយាយម៉្យាងទៀត ការរកឃើញថា អ.វ.ត.ក ខ្វះយុត្តាធិការលើអ្នកស្រី អ៊ឹម ចែម ដោយសារអ្នកស្រីមិនមែនជាមេដឹកនាំជាន់ខ្ពស់ ហើយក៏មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុត[89] រារាំងសហចៅក្រមស៊ើបអង្កេតក្នុងការលើកឡើងអំពីលទ្ធភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អ្នកស្រី[90] ។

៦៧. ដោយសារតែភាពតឹងរ៉ឹងទាំងនេះ និងការសន្មតថាគ្មានទោស អ្នកស្រីអ៊ឹម ចែម មានសិទ្ធិទទួលបានការអាស្រ័យផលលើភាពគ្មានទោសរបស់ខ្លួន ហើយទាំងសហព្រះរាជអាជ្ញាអន្តរជាតិ និងតួអង្គផ្សេងៗទៀតនៃ អ.វ.ត.ក គឺសុទ្ធតែមិនអាចរំលោភបំពានលើការសន្មតនេះបានឡើយ ។ នៅក្នុងករណីទាំងនេះ រាល់សេចក្តីសន្និដ្ឋាន *ហួសពីដែនអំណាចខ្លួន* ទាំងអស់ដែលទាក់ទងទៅនឹងការទម្លាក់កំហុស*បណ្តោះអាសន្ន*លើអ្នកស្រី អ៊ឹម ចែម គួរតែរក្សាទុកជាការសម្ងាត់ដដែល ។ ទោះក្នុងករណីណាក៏ដោយចុះ ចំពោះហេតុផលនានាដែលបានលើកឡើងខាងលើនៅកថាខណ្ឌ២២ ដល់ ២៨ សហចៅក្រមស៊ើបអង្កេតមានសុឆន្ទានុសិទ្ធិក្នុងការបដិសេធមិនដាក់បង្ហាញនូវសេចក្តីសន្និដ្ឋានដែលបង្កការប៉ះពាល់ធ្ងន់ធ្ងរទាំងនេះទៅសាធារណជន ។

---

[តុលាការបានឈានដល់ការធ្វើសេចក្តីសន្និដ្ឋានដូច្នេះថា ខ្លួនមិនអាចទទួលយកនូវអំណះអំណាងណាមួយដែលបានលើកឡើងដើម្បីបញ្ជូនបន្តទៅ DRC ក្នុងការបង្កើតនូវយុត្តាធិការរបស់ខ្លួន សម្រាប់សំណុំរឿងបច្ចុប្បន្ននេះទេ ហេតុដូច្នេះហើយ យើងក៏មិនអាចចាត់ការលើពាក្យសុំក្រោយៗទៀតដែរ”] [ភ្ជាប់ជា**ឯកសារសំអាង ១៧**] ។ *សូមមើលផងដែរ, សំណុំរឿងរបស់ the Monetary Gold ដែលត្រូវបានដកចេញពីទីក្រុងរ៉ូមនៅឆ្នាំ ១៩៤៣ (ប្រទេសអ៊ីតាលី ទល់នឹង បារាំង, ចក្រភពអង់គ្លេស, ប្រទេសអៀរឡង់ខាងជើង និងសហរដ្ឋអាមេរិក)* (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៥៤) សាលក្រមលើសំណួរបឋម ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៤, ត្រង់ទំព័រ ៣២-៣៣ [ភ្ជាប់ជា**ឯកសារសំអាង ១៨**] ។ សំណុំរឿងអាហ្វ្រិកភាគនិរតី (*សំណុំរឿងរបស់ប្រទេសអេត្យូពៀ ទល់នឹង អាហ្វ្រិកខាងត្បូង, សំណុំរឿងប្រទេសលីបេរីយ៉ា ទល់នឹង អាហ្វ្រិកខាងត្បូង*) (របាយការណ៍របស់ I.C.J. ឆ្នាំ ១៩៦៦) សាលដីកាលើការជំនុំជម្រះដំណាក់កាលទីពីរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៦៦ ត្រង់កថាខណ្ឌ ៥៩ [ភ្ជាប់ជា**ឯកសារសំអាង ១៩**] ។

89 *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ៣២៥ ។

90 *សូមមើលឧទាហរណ៍*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ២៨១-៣១២ [ជាពិសេសត្រង់កថាខណ្ឌ ៣០៧៖ “ភស្តុតាងស្តីពីការទទួលខុសត្រូវ ការប្រព្រឹត្ត និងសិទ្ធិអំណាចរបស់អ្នកស្រី អ៊ឹម ចែម បានបង្ហាញយ៉ាងរឹងមាំថាគាត់អាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបទចោទ”] ។

## V. សំណូមពរសុំធ្វើវិសោធនកម្មលើការកោសលុប

៦៨. ក្រុមការពារក្ដីមិនជំទាស់នឹងដីកាសម្រេចដែលរងការជំទាស់នេះទេ ហើយក៏មិនស្វះស្វែងសុំឱ្យមានការបដិសេធចោលដីកានេះដែរ ។ ទោះជាយ៉ាងណាក្ដី វាជាផលប្រយោជន៍របស់អ្នកស្រី អ៊ឹម ចែម អនុលោមតាមវិធាន២១ នៃវិធានផ្ទៃក្នុង ក្រុមការពារក្ដីសូមធ្វើការលើកឡើងនូវការព្រួយបារម្ភទាក់ទងនឹងការកោសលុបដែលត្រូវបានអនុម័តនៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) សំណៅសាធារណៈ ។ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចកោសលុប ត្រូវបានធ្វើឡើងដោយផ្អែកលើ i) តុល្យភាពរវាងការសម្ងាត់នៃកិច្ចស៊ើបអង្កេតដែលកំពុងបន្ត និងសិទ្ធិទទួលបានព័ត៌មានរបស់សាធារណជន ii) ការបង្ហាញជាសាធារណៈនូវអំណះអំណាងផ្នែកច្បាប់នៃដីកាដំណោះស្រាយ (សំអាងហេតុ) និង iii) ការគោរពសិទ្ធិមានជីវិតឯកជនរបស់អ្នកស្រី អ៊ឹម ចែម និងសិទ្ធិដែលត្រូវបានសន្មតថាគ្មានទោស ។ ដូចដែលបានគូសបញ្ជាក់នៅខាងក្រោម ក្រុមការពារក្ដីស្នើសុំឱ្យអនុវត្តដីកាសម្រេចលើបញ្ហានេះឱ្យបានពេញលេញ ។

៦៩. ចំណុចជាក់លាក់ ក្រុមការពារក្ដីសូមស្នើដោយគោរព សុំឱ្យៈ i) អនុវត្តវិធីសាស្ត្រស្របគ្នាក្នុងការកោសលុបឈ្មោះសាក្សី និងសេចក្ដីសន្និដ្ឋានលើអង្គហេតុ ii) បង្កើនការកោសលុបត្រង់ផ្នែកវិសាលភាពនៃដីកាដំណោះស្រាយ (សំអាងហេតុ) និង iii) កោសលុបចេញសេចក្ដីយោងពីសេចក្ដីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម នៅក្នុងផ្នែកនៃការវិភាគលើអង្គហេតុ និងសេចក្ដីសន្និដ្ឋាន ។ ការធ្វើវិសោធនកម្មតិចតួចទាំងនេះ មិនត្រូវបានសន្មតទុកថាជាការមានកំហុសអង្គច្បាប់ ឬមានកំហុសអង្គហេតុ ឬក៏ជាការរំលោភបំពានលើឆន្ទានុសិទ្ធិនោះទេ ប៉ុន្តែគឺដោយវិធីនៃការកែសម្រួលលក្ខណៈមិនត្រឹមត្រូវនៃអក្សរដែលបោះពុម្ព ដើម្បីធានានូវការអនុវត្តដ៏ទៀងត្រង់ និងការអនុវត្តស្របគ្នានៃដីកាសម្រេចដែលរងការជំទាស់ ។

### ក. ការអនុវត្តវិធីសាស្ត្រស្របគ្នាចំពោះការកោសលុបឈ្មោះសាក្សី និងសេចក្ដីសន្និដ្ឋានលើអង្គហេតុ

៧០. ក្រុមការពារក្តីស្នើសុំការអនុវត្តស្របគ្នាលើ: ទីមួយ លើឈ្មោះ ទុំ សឿន[91] និង ពេជ្រ ជឹម[92] ។ ឈ្មោះទាំងពីរនេះ គប្បីធ្វើការកោសលុបចេញជាដរាប ។ ទីពីរ យោងតាមវិធីសាស្ត្រដែលត្រូវបានអនុម័តដោយសហចៅក្រមស៊ើបអង្កេត ការកោសលុបត្រង់កថាខណ្ឌ១៧៦ នៃដីកាដំណោះស្រាយ (សំអាងហេតុ) គួរតែត្រូវកុំធ្វើការកោសលុប ទោះបីជាមានការចេញផ្សាយឈ្មោះបុគ្គលទាំងពីរដែលទើបតែបានលើកឡើងនេះក៏ដោយ ។ ទីបី ការលើកឡើងត្រង់ផ្នែកទី ៤.៤ ទាំងមូល គឺជាព័ត៌មានសម្ងាត់ទាក់ទងទៅនឹងភស្តុតាង មិនមែនជា "សេចក្តីសន្និដ្ឋានលើអង្គច្បាប់សំខាន់ៗ" ទេ ហេតុដូច្នេះ ផ្នែកនេះគប្បីត្រូវធ្វើការកោសលុបចេញ ។

## ខ. ការបង្កើនការកោសលុបត្រង់ផ្នែក វិសាលភាពនៃដីកាដំណោះស្រាយ (សំអាងហេតុ)

៧១. នៅក្នុងសេចក្តីប្រកាសព័ត៌មានក្រោយពេលដាក់ចេញដីកាដំណោះស្រាយ (ផ្នែកសេចក្តីសម្រេច) សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ដូច្នេះថា:

> សហចៅក្រមស៊ើបអង្កេត និងរៀបចំ ហើយផ្សព្វផ្សាយសំណៅជាសាធារណៈនៃ *សេចក្តីសន្និដ្ឋានផ្លូវច្បាប់សំខាន់ៗ* ពាក់ព័ន្ធបញ្ញាយុត្តាធិកាបុគ្គលនៅពេលចេញសេចក្តីសំអាងហេតុពេញលេញ[93] ។

៧២. ត្រង់ផ្នែក៥.១ បរិយាយពីការពិចារណាបឋមលើផ្នែកទី៥ ស្តីពីភស្តុតាងទាក់ទងនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ប៉ុន្តែពុំត្រូវបានចោទប្រកាន់នោះ តម្រូវឱ្យមានការធ្វើសេចក្តីសន្និដ្ឋានលើអង្គច្បាប់សំខាន់ៗ ដែលចំណុចនេះគួរតែត្រូវបានផ្សព្វផ្សាយឱ្យសាធារណជនបានដឹងឮ ។ ដូច្នេះ ការកោសលុបលើផ្នែកទាំងមូល គួរតែត្រូវបានដកចេញវិញ ។ ចំណុចទាំងនេះគឺជារឿងសំខាន់ជាង ពីព្រោះសហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងភាគច្រើន

---

[91] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ១១៩ និង ១៦៥(ច) ។

[92] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ១៤៦, ១៤៨ និង ១៥៧ ។

[93] 'សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង[អ្នកស្រី] អ៊ឹម ចែម' ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧ អាចចូលមើលបាននៅ៖ https://www.eccc.gov.kh/articles/39515 (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)។

ក្នុងដីកាសន្និដ្ឋានស្ថាពររបស់គាត់ទៅលើភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មមួយចំនួន ដែលឧក្រិដ្ឋកម្មទាំងនេះ មិនត្រូវបានចោទប្រកាន់ឡើយ ហើយក្រុមការពារក្តីបានដាក់ចម្លើយតបយ៉ាងស៊ីជម្រៅលើបញ្ហានេះ ។ ការធ្វើដូច្នេះ នឹងជួយពន្យល់ពីសេចក្តីសន្និដ្ឋាននានានៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) ឱ្យបានកាន់តែពេញលេញជាងមុន ដោយមិនបង្កឱ្យមានការខូចប្រយោជន៍របស់ភាគីណាមួយឡើយ ដែលនេះគឺជាការធានានូវកេរ្តិ៍ដំណែលច្បាប់ត្រឹមត្រូវ និងក៏ដើម្បីជាប្រយោជន៍ដល់តុលាការកម្ពុជាទាំងមូលផងដែរ ។

### គ. កោសលុបចេញសេចក្តីយោងដែលជាសេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម នៅក្នុងផ្នែកនៃការវិភាគលើអង្គហេតុ និងសេចក្តីសន្និដ្ឋាន

៧៣. មាត្រា១៤(៣)(ឆ)តម្រូវថា ក្នុងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមា រាប់បញ្ចូលទាំង "ការមិនត្រូវបានបង្ខិតបង្ខំឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ" ដែលចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានសម្រេចយ៉ាងត្រឹមត្រូវថា សេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម គួរតែត្រូវបានផ្តល់ទម្ងន់តិចតួចជាងការស្តាប់ចម្លើយដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[94] ។ ទោះជាយ៉ាងណាក៏ដោយ ហេតុផលមួយចំនួនដែលបានគូសបញ្ជាក់ខាងក្រោម ការកោសលុបបច្ចុប្បន្ន មានឥទ្ធិពលដែលអាចរារាំងដល់ការការពារនេះ ។

៧៤. នៅក្នុងសំណៅកោសលុបសាធារណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) ផ្នែកទាំងមូលនៃការវិភាគអង្គហេតុ និងសេចក្តីសន្និដ្ឋាន គឺត្រូវបានកោសលុបផ្នែកខ្លះនៃកិច្ចសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម និងករណីលើកលែងជាក់ស្តែងមួយចំនួនទៀត[95] ។ ការយោងនៅជើងទំព័រចាប់ពីលេខរៀង

---

[94] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ត្រង់កថាខណ្ឌ ១៣៩ ។

[95] *សូមមើល*, ដីកាដំណោះស្រាយ (សំអាងហេតុ) ជើងទំព័រលេខ ៣២១ និង ៣២៧ (*យោងទៅលើ* ប្រតិចារិកនៃការជំនុំជម្រះលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ ធ្វើនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥, ឯកសារ **D219/494.1.8**, ERN 01132282-83, 01132311) ជើងទំព័រលេខ ៣២៥ (*យោងទៅលើ* កិច្ចសម្ភាសន៍ជាមួយជនសង្ស័យ អៀង សារី ហៅ វ៉ាន់

២៥៦ ដល់ជើងទំព័រលេខ ៧៣៥ សហចៅក្រមស៊ើបអង្កេតបានសំអាងលើបទសម្ភាសន៍របស់អ្នកស្រី អ៊ឹម ចែម ចំនួន ១៦ លើក ។ ក្រៅពីយោងលើសេចក្តីថ្លែងការណ៍មួយធ្វើនៅឆ្នាំ ២០១២[96] សេចក្តីថ្លែងការណ៍ដទៃទៀត ដែលត្រូវបានយោងដែរ នោះ មិនមានជាឯកសារសាធារណៈទេ ។

៧៥. ការបង្ហាញនូវព័ត៌មានដូច្នេះ មានអានុភាពបង្កើតឱ្យមានការកាត់យល់ខុស ដែលវាហាក់ដូចជាថា សេចក្តីថ្លែងការណ៍របស់អ្នកស្រី អ៊ឹម ចែម ត្រូវបានសម្រេចប្រើប្រាស់ជាភស្តុតាងចម្បងគាំទ្រដល់ការវិភាគអង្គហេតុ និងសេចក្តីសន្និដ្ឋាន ដែលបានពណ៌នានៅក្នុងដីកាដំណោះស្រាយ (សំអាងហេតុ) បូករួមទាំងសេចក្តីសន្និដ្ឋាននានាដែល *ហួសពីដែនអំណាចច្បាប់* ។ ក្រុមការពាក្តីសូមស្នើថា សេចក្តីថ្លែងការណ៍ទាំងនេះ គួរតែត្រូវបានធ្វើការកោសលុប ។ ការធ្វើដូច្នេះ នឹងធានានូវការប្រឆាំងលើភាពអយុត្តិធម៌ និងនាំឱ្យខូចប្រយោជន៍ដែលអាចកើតឡើងដោយសារតែឥទ្ធិពលនៃការធ្វើឱ្យយល់ខុស ។

## VI. សំណើដែលត្រូវស្នើសុំ

ចំពោះហេតុផលដែលបានលើកឡើងខាងលើ ក្រុមការពារក្តីសូមស្នើដោយគោរពទៅអង្គបុរេជំនុំជម្រះមេត្តា:

i) ច្រានចោលបណ្តឹងឧទ្ធរណ៍ ប៉ុន្តែអនុញ្ញាតតាមសំណើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញនៃដីកាសម្រេចដែលរងការជំទាស់ ក៏ដូចជាបណ្តឹងឧទ្ធរណ៍ ព្រមទាំងចម្លើយតប និង

---

ធ្វើនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ឯកសារ **D1.3.29.1**, ERN 00350208 ។ ប្រតិចារិកនៃកិច្ចសម្ភាសន៍រវាង Steve Heder ជាមួយលោក អ៊ុក ប៊ុនឈឿន ដោយ ឯកសារ **D6.1.529** ជើងទំព័រលេខ ៣៣១ (*យោងទៅលើ* ឧបសម្ព័ន្ធ៩៖ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ កិច្ចសម្ភាសន៍ជាមួយ ឈិត យឿក ធ្វើនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ **D67.9**, ERN 00731142) ។ ត្រង់ជើងទំព័រលេខ ៣៤៧, ៣៤៨, ៣៥៣, ៣៥៥, ៣៥៦, ៣៥៧ (*យោងទៅលើ* ឯកសារច្បាប់របស់ ប.ក.ក មានចំណងជើងថា "លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា" ខែ មករា ឆ្នាំ ១៩៧៦, ឯកសារ **D1.3.20.1**) ។ ត្រង់ជើងទំព័រលេខ ៣៥៨, ៣៥៩ (*យោងទៅលើ* ទស្សនាវដ្តីរបស់ ប.ក.ក មានចំណងជើងថា "ទង់បដិវត្តលេខពិសេស" ខែ តុលា - វិច្ឆិកា ឆ្នាំ ១៩៧៧ ឯកសារ **D6.1.740** ) ។

[96] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយអ្នកស្រី អ៊ឹម ចែម ធ្វើនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **E305/13.23.330** អាចចូលមើលបាននៅ: https://www.eccc.gov.kh/sites/default/files/documents/courtdoc/2015-06-11%2013:07/E305_13.23.330_EN.PDF

ii) ផ្ដល់ការអនុញ្ញាតតាមសំណើរបស់ក្រុមការពារក្ដី សុំធ្វើវិសោធនកម្មសំណៅកោសល្យុប សាធារណៈនៃដីកាដំណោះស្រាយ (សំអាងហេតុ) ។

សូមមេត្តាទទួលយកសារណានេះដោយគោរព ៕

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៧

សហមេធាវីការពារក្ដីអ្នកស្រី អ៊ឹម ចែម

| | |
|---|---|
| [ហត្ថលេខា] | [ហត្ថលេខា] |
| ______________ | __________________ |
| ប៊ិត ស៊ាងលីម | Wayne JORDASH, QC |